# អក្ខរវិធីសំណាងក្នុងភាសាខ្មែរ *

គេអាចប្រើអក្សរតាឡាំងដើម្បីសងអក្សរឬសូរក្នុងភាសា។ អក្សរឡាតាំងសងអក្សរនៃភាសាណាមួយមានសារៈសំខាន់សម្រាប់អ្នកស្រាវជ្រាវឬអ្នកដែលចង់ស្វែងយល់ពីភាសាណាមួយនោះ។ វិធីបែបនេះគេហៅថាអក្ខរវិធីសំណាង (translitération)។ មួយបែបទៀត គេប្រើអក្សរឡាតាំងដោយផ្សំនឹងសញ្ញាពិសេសមួយចំនួនដើម្បីកត់សូរភាសា។ វិធីទីពីរនេះច្រើនប្រើដោយអ្នកជំនាញផ្នែកភាសាក្នុងការសិក្សាភាសា ជាពិសេស ភាសាមិនមានអក្សរ។ វិធីបែបនេះគេហៅថាប្រតិចារឹកសូរវិទ្យា (transcription phonétique)។

ការផ្លាស់ប្ដូរផ្នែកណាមួយនៃសង្គមមិនអាចប្រព្រឹត្តទៅបានស្រួលនោះ។ មានកម្លាំងជំទាស់ពីរនៅពេលគេមានបំណងផ្លាស់ប្ដូរសង្គម។ កម្លាំងទីមួយកើតចេញពីស្ថាប័ន កម្លាំងជំទាស់ទីពីរកើតពីផ្នែកផ្លូវចិត្ត។[1] មានរលកព្រឹត្តិការណ៍ធំៗពេលការផ្លាស់ប្ដូរកើតឡើង។

បព្វជិតគ្រិស្ដសាសនា **អាឡិចសង់ដ្រ៍ ដឺ រ៉ូដស៍** (១៥៩៣-១៦៦០) បានបង្កើតអក្សរតាឡាំងដែលគេហៅថា អក្សរកុកងឺ (chữ Quốc ngữ "អក្សរជាតិ") ជំនួសអក្សរចិនដែលវៀតណាមយកមកប្រើសម្រាប់ភាសាខ្លួន។ ក្រៅពីវៀតណាម ភាសានៅអឺរ៉ុបចាប់មានឥទ្ធិពលលើប្រទេសនានានៅតំបន់អាស៊ីអាគ្នេយ៍ក្រោយអឺរ៉ុបពង្រីកអាណានិគមនិងជំនួសឥទ្ធិពលឥណ្ឌានិងចិនចាប់ពីសតវត្សរ៍ទី១៥មក។ ដូច្នេះ វាមិនមែនជារឿងភ្ញាក់ផ្អើលទេដែលភាសានៃបណ្ដាប្រទេសទាំងមានពាក្យមានប្រភពពីភាសាអឺរ៉ុបច្រើន។

---

* អ្នកនិពន្ធសូមថ្លែងអំណរគុណឯកឧត្ដមបណ្ឌិត **ជួរ គារី**, លោក **គុយ វិន**, លោកស្រី **អ៊ឹង ម៉ាល័យ**, លោក **អ៊ុយ វិចិត្រ** ដែលបានជួយរកឯកសារនិងរូបថត និង សម្រួលកិច្ចការទាក់ទងអត្ថបទនេះ។ យើងបានភ្ជាប់ឯកសារមួយចំនួននៅឧបសម្ព័ន្ធ។ ក្នុងអត្ថបទ យើងបានរំលេចកិច្ចការខ្លះរបស់អ្នកប្រាជ្ញរាជបណ្ឌិតខ្មែរដែលយើងបានរៀនសូត្រពីលោកឬធ្វើការងារជាមួយក្នុងរយៈពេលប្រមាណ២០ឆ្នាំចុងក្រោយនេះ។ កិច្ចការរបស់បុគ្គលដែលយើងលើកមកច្រើនអស់លោកអ្នកប្រាជ្ញដែលបានចែកស្ថានទៅ ដោយយើងបានបញ្ចូលឆ្នាំកំណើតនិងឆ្នាំមរណភាពក្នុងវង់ក្រចក។ ដោយឡែក ឯកសារក្នុងឧបសម្ព័ន្ធនិងការរំគាយសេចក្ដីលើចំណុចមួយចំនួនទាក់ទងនឹងភាសាខ្មែរក៏ដូចសង្គមខ្មែរនោះគឺដោយសារយើងយល់ថាវាអាចជាពត៌មានមួយចាំបាច់សម្រាប់អ្នកស្រាវជ្រាវនាពេលបច្ចុប្បន្នឬអនាគត។ ទោះយ៉ាងក្ដី យើងសូមទទួលខុសត្រូវរាល់ការខ្វះចន្លោះទាំងអស់ដែលកើតមានក្នុងអត្ថបទនេះ។

[1] លោក **សេយម៉រ សារ៉ាសុន** (១៩១៩-២០១០) ស្ថាបនិកនៃចិត្តវិទ្យាសហគមន៍ បានកត់សម្គាល់ថាការព្យាយាមដើម្បីជួសជុល ឬ បង្ការបញ្ហាអស្ថិរភាពសង្គមនានាជួបការជំទាស់ខាងស្ថាប័ននិងខាងចិត្តសាស្ត្រ (institutional and psychological opposition)។ លោកបានបញ្ជាក់ថាអាកប្បកិរិយាដែលមានជាប់យូរយាមកហើយ, ប្រពៃណី និង ភាពនឹងថ្កល់របស់ស្ថាប័នមិនផ្លាស់ប្ដូរទៅណា ជាហេតុនាំឱ្យមានការជំទាស់។ ចំណុចទីពីរទាក់ទងនឹងការដឹកនាំក្នុងការព្យាយាមកែសង្គមដែលទាមទារការឈ្វេងយល់ថាតើអ្នកដែលជំទាស់នោះគិតនិងយល់យ៉ាងណា។ ទីបី បើទោះបីកត្តាទាំងពីរខាងដើមមិនមានបញ្ហាក្ដី ក៏គេមិនប្រាកដថានឹងទទួលបានលទ្ធផលគាប់ចិត្តនោះដែរ។ ជាចុងក្រោយ លោកយល់ថាការជំទាស់នឹងការព្យាយាមផ្លាស់ប្ដូរសង្គមច្រើនកើតពីការមានបញ្ញត្តិកម្មផ្សេងៗគ្នាលើប្រភពនៃបញ្ហា ("differing conceptions of etiology"); Cf. Seymour B. Sarason, *Political Leadership and Educational Failure,* (California: Jossey-Bass Inc., Publishers, 1998), pp. 3-4.។
យើងយល់ថាបញ្ហាទាំងអស់ក្នុងសង្គមមនុស្សមិនមែនមិនអាចដោះស្រាយដោះទេ។ នៅពេលដែលបញ្ហាមិនអាចដោះស្រាយបាន វាមិនមែនជាបញ្ហារបស់បញ្ហាទៀតទេ តែ វាជាបញ្ហាមនុស្ស។ប្រសិនបើអ្នកពាក់ព័ន្ធយកមូលដ្ឋានប្រយោជន៏រួម ឬ មនុស្សជាតិជាធំបូកផ្សំនឹងការជម្រុះមានះផ្ទាល់ខ្លួនខ្លះៗនោះ យើងអាចដោះស្រាយបញ្ហានានាបានតាមលំដាប់លំដោយនិងតាមកាលៈទេសៈ៕

តាហ្កាឡុក ដែលជាភាសាជាតិរបស់ហ្វីលីពីន មានពាក្យអេស្ប៉ាញប្រហែល២០%[2]។ ហ្វីលីពីនស្ថិតក្រោមអាណានិគមអេស្ប៉ាញជាង៣០០ឆ្នាំ។ នៅឆ្នាំ១៩០៨ ប្រជាជនវ័យក្មេងនៅឥណ្ឌូណេស៊ីបានជំទាស់នឹងហូឡង់ដែលចង់ប្រើភាសាហូឡង់ជាភាសាជាតិសម្រាប់ប្រទេសឥណ្ឌូណេស៊ី[3]។ អ្នកស្រាវជ្រាវខ្លះអះអាងថាពាក្យឥណ្ឌូណេស៊ីដែលអាចឱ្យគេដេញទៅរកប្រភពភាសាពីហូឡង់មានចំនួន២០%[4]។ ប្រទេសនេះស្ថិតក្រោមអាណានិគមហូឡង់ប្រែល៣៥០ឆ្នាំ។

នៅសតវត្សទី១៤ ភាសាម៉ាឡេ (Bahasa Melayu) ជាភាសារួមសម្រាប់នគរឬដែនដីស្ថិតស្ដេចស៊ុលតង់មល្លកា។ នគរឬដែនដីទាំងនេះត្រូវនឹងប្រទេសម៉ាឡេស៊ី ឥណ្ឌូណេស៊ី ប្រ៊ុយណេ និង សិង្ហបុរី។ ប៉ុន្តែ ក្រោយទទួលបានឯករាជ្យភាសានេះបាននិវត្តជា Bahasa Melayu សម្រាប់ភាសាស្តង់ដាម៉ាឡេ និង Bahasa Indonesia សម្រាប់ភាសាផ្លូវការឥណ្ឌូណេស៊ី។

នៅឆ្នាំ១៩៧២ ថ្វីត្បិតប្រទេសឥណ្ឌូណេស៊ីមានបំណងចង់ប្រើអក្ខរាវិរុទ្ធ តែ ម៉ាឡេស៊ី, ដែលធ្លាប់ស្ថិតក្រោមអាណានិគមអង់គ្លេសប្រហែល១៥៦ឆ្នាំ, នៅប្រើអក្សរវិរុទ្ធមួយចំនួនផ្សេងពីឥណ្ឌូណេស៊ី។ ឧទាហរណ៍មួយចំនួន ដូចជា សូរអង់គ្លេស 'c' នៅជា 'ch' ក្នុងភាសាស្តង់ដាម៉ាឡេ ហើយ ក្លាយជា 'c' ចំពោះពាក្យមាន 'tj' ក្នុងភាសាឥណ្ឌូណេស៊ី[5]។

ដោយឡែក ពាក្យខ្មែរប្រមាណ៣១%មានប្រភពពីភាសាសំស្ក្រឹត-បាលី[6]។ កំណែទម្រង់ភាសាដំបូងកើតនៅពេលធ្វើវចនានុក្រមខ្មែរដំបូងក្នុងឆ្នាំ១៩១៥។ ក្រោយការពិភាក្សាគ្នាយ៉ាងផុលផុស ក្រុមជំនុំវចនានុក្រមខ្មែរពេលនោះបានសម្រេចពាក្យមានប្រភពពីភាសាបាលីសំស្ក្រឹតត្រូវសម្របតាមអក្ខរាវិរុទ្ធបែបភាសាបាលីសំស្ក្រឹតដើម[7]។

នៅឆ្នាំ១៩៤២ លោក **ហ្សក្រស៍ ហ្គោទីយេរ** (១៩០១-១៩៨៧) បានស្នើគំនិតចំនួន៣ថ្វាយសម្ដេចព្រះ**នរោត្ដម សីហនុ** ក្នុងការងាររបស់លោកជាអគ្គទេសាភិបាលនៅប្រទេសកម្ពុជា។ ទីមួយ ការធ្វើដំណើរជុំវិញប្រទេសកម្ពុជា ដែលក្នុងនោះ មានការឆ្លងកាត់ភ្នំដងរែក ការឆ្លងកាត់ប្រទេសវៀតណាមពីខាងត្បូងទៅខាងជើង ហើយ ឆ្លងចូលដីប្រទេសឡាវនិងចុះមកខាងត្បូងចូលក្នុងប្រទេសកម្ពុជាវិញតាមខេត្តស្ទឹងត្រែង។ ទីពីរ ចង្កោមនៃការកែទម្រង់ដែលមានរ៉ូម៉ាំងនីយកម្មភាសាខ្មែរ, ការប្រើប្រតិទិនសុរិយគតិនិងការចូលឆ្នាំខ្មែរនៅថ្ងៃទី១ខែមករា។ ទីបី ការផ្សំផ្គុំរវាងសម្ដេចព្រះ**នរោត្ដម សីហនុ** និង កញ្ញា **ជួន ជឿម** នៃត្រកូលឧកញ៉ាចៅហ្វាវាំង **ជួន**។ សម្ដើគំនិតទាំង៣សម្រេចបានតែគំនិតទីមួយប៉ុណ្ណោះ។ សម្ដើគំនិតទីពីរត្រូវលុបចេញដោយព្រះរាជក្រឹត្យខែមីនាឆ្នាំ១៩៤៥[8] នាពេលនោះ មានចលនា

---

[2] https://vamospanish.com/discover/the-spanish-influence-on-filipino-culture-and-language/#:~:text=Spain's%20colonization%20of%20the%20Philippines,Tagalog%20words%20originating%20from%20Spanish. (១៨.១២.២៣)

[3] https://linguistics.byu.edu/classes/Ling450ch/reports/bahasa.htm (១៨.១២.២៣)

[4] https://en.wikibooks.org/wiki/Dutch_Empire/Language (១៨.១២.២៣)

[5] https://ling-app.com/ms/malay-and-indonesian/(១៨.១២.២៣)

[6] សេ អឿន, *ពាក្យកម្ចីសំស្ក្រឹត-បាលីក្នុងភាសាខ្មែរទំនើប*, បរិញ្ញាបត្រជាន់ខ្ពស់, រាជបណ្ឌិត្យសភាកម្ពុជា, ២០០២, ទំ.៩២។

[7] តាមការសង្កេត សមាសភាពក្នុងក្រុមជំនុំដែលមានក្នុង *វចនានុក្រមខ្មែរ* គ្រាទី៥ ជាការសរុបរវាងសមាសភាពក្រុមជំនុំឆ្នាំ១៩១៥និងក្រុមជំនុំឆ្នាំ១៩២៦។ តាម*ស្នាព្រះហស្តក្រោយបង្អស់នៃសម្ដេចព្រះសុមេធាធិបតី ជួន ណាត* ត្រង់ព្រះរាជជីវប្រវត្តិ គេដឹងថា សម្ដេចព្រះសង្ឃរាជជាសមាជិកនៃក្រុមជំនុំក្នុងឆ្នាំ១៩១៩ ក្នុងឋានៈជាលេខាធិការ ក្នុងអាយុ៣៦ឆ្នាំ ហើយ នៅឆ្នាំ១៩២៧ ទ្រង់ទទួលធ្វើវចនានុក្រមតែមួយព្រះអង្គឯងរៀងមក។
ចំពោះសមាជិកក្រុមជំនុំលើកដំបូងនិងសម័យបន្ទាប់ យើងបានភ្ជាប់ក្នុងក្នុងឧបសម្ព័ន្ធនូវអត្ថបទរបស់លោក **ហ្សក សឺដែស** ដែលជាគ្រូមួយរូបនៃសម្ដេចព្រះសង្ឃរាជ **ជួន ណាត** និង សម្ដេចព្រះសង្ឃរាជ **ហួត តាត** កាលព្រះអង្គទាំងពីរនិមន្តទៅសិក្សាភាសាសំស្ក្រឹតនិងវិជ្ជាផ្សេងទៀតនៅទីក្រុងហាណូយ។

[8] នរោត្ដម សីហនុ, *អនុស្សាវរីយ៍ផ្អែមល្ហែម និង ជូរចត់*, បកប្រែដោយ នរោត្ដម រណឫទ្ធិ, ១៩៨០, ទំ.៤៧-៥២។

សង្គមតវ៉ាប្រឆាំងនឹងបារាំងចំពោះការយកអក្សរឡាតាំងសរសេរពាក្យខ្មែរ ឬ ហៅថា “កុកងឺខ្មែរ” ។វរជនខ្មែរពេលមានដូចជា លោកអាចារ្យ **ហែម ចៀវ**, លោកអាចារ្យ **ប៉ាង ខាត់**, លោកអាចារ្យ **សួរ ហាយ**, លោកអាចារ្យ **អ៊ុក ជា**, លោកអាចារ្យ **ខៀវ ជុំ**, លោក **សឺន ង៉ុកថាញ់**, លោក **ប៉ាច ឈឿន**, លោក **ស៊ឹម វ៉ារ**, លោក **ឈឹម ក្រសេម**, លោក **ជុំ មួង**, លោក **ប៊ុណ្ណចន្ទ មល** ជាដើម។ ពេលនោះមិនត្រឹមតវ៉ារឿងភាសាខ្មែរប៉ុណ្ណោះទេ តែ គោលបំណងធំគឺចង់បណ្តេញបារាំងចេញពីប្រទេស[9]។

ចុងឆ្នាំ១៩៦៧ មានការកែសម្រួលមួយទៀតទាក់ទងនឹងភាសាខ្មែរ នៅគ្រាបោះពុម្ពលើកទី៥ ដែលក្រុមជំនុំស្ថិតក្រោមការទទួលខុសត្រូវរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** និង សមាជិក៤រូប គឺ ព្រះសាសនមុនី **កិម តូរ**, ព្រះបិដកធម្ម **អ៊ុម ស៊ុម**, លោក **ញូង សៀង** និង លោក **ថោង សំអ៊ី**។ តាមនិទានសម្រាប់គ្រាបោះពុម្ពលើកទី៥នោះ ក្រុមជំនុំបានសម្រេចថាពាក្យជាកិរិយាសព្ទឬគុណនាមដែលសរសេររាយតួ កាលណាក្លាយជានាម ពាក្យទាំងនេះសរសេររាយតួដែរ ហើយ បើសរសេរត្រួតតួ កាលណាក្លាយជាកិរិយាហេតុ ពាក្យទាំងនេះសរសេរត្រួតតួដែរ។ ការសម្រួលសំណេរមួយទៀតជាការបន្ថយសំណេរអក្ខរាវិរុទ្ធពីរបីបួនបែបឱ្យថយកាន់តែតិច។ គំនិតគោលទាំងបីរបស់ក្រុមជំនុំនៅឆ្នាំ១៩១៥និងឆ្នាំ១៩៦៧ជាគំនិតកំណែទម្រង់សំខាន់មួយក្នុងភាសាខ្មែរដែលបន្សល់ជាមត៌កដល់បច្ចុប្បន្នកាល។

យើងនឹងរំឭកខ្លះពីការវិវត្តអក្សរនិងភាសាក្រោយសម័យអង្គរ និង ប្រវត្តិការប្រើអក្សរឡាតាំងតាងអក្សរខ្មែរក្នុងសង្គមខ្មែរ។ ជាចុងក្រោយ យើងបានសំយោគគំនិតដែលមានស្រាប់និងស្នើជាប្រព័ន្ធអក្សរឡាតាំងមួយសម្រាប់អក្សរខ្មែរ។

## ១. ប្រវត្តិខ្លះៗស្តីពីការវិវត្តអក្សរក្រោយសម័យអង្គរ

យោងលើសិលាចារឹកនគរវត្ត យើងសង្កេតឃើញថាសញ្ញាស្រៈដែលយើងមានសព្វថ្ងៃចាប់ផ្តើមប្រើពេញលេញហើយ ថ្វីត្បិតតែមានបណ្តារូប ឬ កលរូប (allomorphes) ចំពោះសញ្ញាស្រៈខ្លះក្តី ៖

- ឹ និង ឺ ត្រូវបានប្រើក្នុងសំណរខ្មែរនៅសតវត្សរ៍ទី១៨ ដូចមានក្នុងសិលាចារឹកនគរវត្តលេខ ២០, ៣១, ៣៧, ៣៨ ជាដើម;
- ួ ក្នុង ផ្ទួស្ស (IMA ៣៨:៧);
- ឿ ក្នុង ប្ចោម្ពេិង (IMA ៨:១៩); ទទួលប្រយុត្នរឿនរុង (**ល្បើកអង្គរវត្ត** ទំ.[៨៨]);
- ៀ ក្នុង វេ្យិម (IMA ១៧:៦); ត្តុំទៀងលេយ (IMA ២៦:១០); បេ្យីម្ម (IMA ៣៧:២៧);
- ើ ក្នុង ទំរោកវេិស្សបម្ងល (IMA ៣៨:១២); កើតរ្វិមស្ពាណ្ឌ (IMA ៣៨:១០);
- ែ ក្នុង រទែះ (IMA ៣៨:៥០);
- ាំ ក្នុង ភ្លេបូភ្លាំង (IMA ៣៨:២១);

ដោយឡែក ចំពោះវគ្គ ដ យើងសង្កតឃើញថា នៅសិលាចារឹកនគរវត្ត ក្នុងរវាងសតវត្សរ៍ទី១៨ គេឃើញមានអក្សរវគ្គនេះសព្វគ្រប់ហើយ ៖

[9] ប៊ុណ្ណចន្ទ មល, *គុកនយោបាយ*, ភ្នំពេញ, ១៩៧១, ទំ.៨-២៨។

- ដ ក្នុង ត្រៃបីដក (IMA ៣៨:៦);
- ឋ ក្នុង កហ្វាបាម្មិ (IMA ២៤:៣៩);
- ឌ ក្នុង បណ្ឌិតឌិន (IMA ២៤:២៥);
- ឍ ក្នុង វិឍប្តិន (IMA ៣២:២៦);
- ណ ក្នុង កូណាប្តែវ (IMA ៨:៤២) ជាដើម។ នៅបណ្តាសិលាចារឹកនគរវត្ត ស្ទេរសិលាចារឹកច្រើនប្រើ ទ ជំនួស ឌ, ត ជំនួស ដ។

ជាការកត់សម្គាល់ សូរ ទ ក្នុង អន្ទិត អាចកើតតាំងពីសម័យកណ្តាលនិងចាក់ឫសគល់នៅដើមសតវត្សរ៍ទី១៩។ ក្នុងល្បើកអង្គរវត្ត គេឃើញមានពាក្យ បន្ទិត ក្នុងកំណាត់ល្បះ ... ដែបដិដ៍សោមបន្ទិត ជុំមផ្លូដ៍ផ្ទៀដ៍មៀដ៍មេិលគ្នា (ទំ.[៧៣])។ ក្នុងសិលាចារឹកនគរវត្ត ដែលតាមឧទាហរណ៍មួយនៃសិលាចារឹក មទិតតៃ្ស (IMA ២១:៤០)។

នៅដើមសតវត្សរ៍ទី១៩ លោក **ហង់រី ហ្គ័រដង់**, អធិការប្រឹក្សាការអប់រំសាធារណៈនៅឥណ្ឌូចិន, បានកត់សម្គាល់លើយុវជនខ្មែរដែលចូលបួសនៅតាមបណ្តាវត្តអារាម។ លោកថា នៅប្រទេសកម្ពុជា មានអារាមជាង២ពាន់និងបព្វជិតដ៏ច្រើន។ យុវជនចូលបួសរៀនអក្សរដើម្បីមើលគម្ពីរសាស្ត្រាបាឡី។ ព្រះសង្ឃដែលជាអ្នកបង្រៀនត្រូវបានទទួលការគោរពដ៏ក្រៃលែង។ នៅរាជធានីភ្នំពេញ មានការបង្រៀនកម្រិតខ្ពស់ដែលគេអាចរៀនភាសាបាឡី។ លោកថា មានទម្រង់ជារាជបណ្ឌិត្យសភានៃព្រះរាជវាំងដែលជាពួកបណ្ឌិត ([I]l y a même une sorte d'Académie du palais, celle des Bantits, formée des meilleurs lettrés)។[10]

នៅដើមសតវត្សរ៍ទី១៩ ជើង ដ ត្រូវបានជំនួសដោយជើង ឌ ដូចក្នុងសំណេរ *រឿងបន្ទាំមតាមាស* បោះពុម្ពរវាងឆ្នាំ១៩០៧។ ក្នុងសៀវភៅនេះ ថ្វីត្បិតសំឡេងពួកព្យញ្ជនៈអ អ៊ លោកបែងចែកច្បាស់ ការយករូបអក្សរតាងសូរនៅមិនចែកច្បាស់។ ពួកអ លោកសរសេរ ដ ដូចជា ដំណាង, ដំឡាសទ្វា, ព្រះត្រៃបិដក់, ស្រុកបាត់ដំបង, ស្រុកឱដុងមានជៃ្យ, ...។ ដូច្នេះ ក្នុងគំនិតលោក បញ្ហាសូរខ្យល់មិនមានបញ្ហានោះទេ។

ពាក្យដែលមានសូរ ដ ហើយ ត្រូវប្រើជាជើងនោះ លោកប្រើជើង ឌ ដូចជា ក្តោង, ដ្ឋបម្តេប់, ធម្ពា, ជន្ទើម, ផ្ទុគ្នា, ស្តេប់,... ក៏មាន; ពេលខ្លះ លោកប្រើជើង ត សម្មតជាជើង ត ផង ជាជើង ដ ដូចជា ស្តេប់, អន្តូង, សាស្ន៍គ្រិះស្តាំង, បាញ់បន្តក់គ្រាប់បែក, ... ក៏មាន; ពេលខ្លះ ប្រើជើង ត និង ជើង ឌ លាយគ្នា ដូចជា ស្តេប់ផែន្តី, ...ក៏មាន។ ស្របគ្នានេះ គេនៅរក្សានិរុត្តិរបស់ពាក្យ ដូចជា បែស្តា ជាដើម។

ចំពោះវណ្ណយុត្តិ[11] សញ្ញាភាសាខ្មែរប្រើបច្ចុប្បន្ន ភាគច្រើនកើតនៅសម័យក្រោយអង្គរ ដូចជា មូសិកទន្ត, ត្រីសព្ទ, រស្សសញ្ញា, សំយោគសញ្ញា, របាទ, ទណ្ឌឃាត, យុគលពិន្ទុ, លេខទោ, លេខអស្តា។ លោក **អៀវ កើស** មិនរាប់

---

[10] Henri Gordon, *Enseignements des indigènes en indochine,* (Paris : Société Générale d'imprimerie et d'édition levé, 1910), p. 4.

[11] ក្នុងវចនានុក្រមខ្មែរ១៩៦៧-១៩៦៨ លោករាប់វណ្ណយុត្ត ១៩ ៖ ១- វិសជ៌នី ឬ វិសគ៌ៈ ឬក៏ រះមុខ (ះ); ២- មូសិកទន្ត ឬ ធ្មេញកណ្តុរ ( ៉ ) ; ៣- ត្រីសព្ទ ( ៊ ); ៤- ទណ្ឌឃាត ឬ បដិសេធ ( ៍ ) ; ៥- របាទ ឬ រេផៈ ( ៌ ); ៦- រស្សសញ្ញា ឬ បន្តក់ ( ់ ); ៧- សំយោគសញ្ញា ( ័ ); ៨- លេខទោ ឬ អាមេណ្ឌិតសញ្ញា ( ៗ ); ៩- លេខអស្តា ( ៏ ); ១០- កាកបាទ ឬ ជើងក្អែក (+); ១១- កុក្កុដនេត្រ ឬ ភ្នែកមាន់ (៙); ១២- របះ( ។ ); ១៣- របះចប់ ឬ របះបរិយោសាន ( ៕ ); ១៤- គោមូត្រ ( ៚ ); ១៥- វ៉ាត់ ឬ គាប ( } ); ១៦- រជ្ជុសញ្ញា ( – ); ១៧- មច្ឆណ្ឌសញ្ញា ឬ ពងត្រី (. . .) ; ១៨- បេយ្យាល ( ។ បេ ។ ) ឬ ( ។ ល ។ ); ១៩- យុគលពិន្ទុ ( : )។

វិសជ្ជនីយ៍ចូលវណ្ណយុត្តិទេ។ លោកប្រកាន់ជំហរលើន័យតាមនិរុត្តិសាស្ត្រថាជា «គ្រឿងសំគាល់កែលំអៀងសម្លេងអក្សរ»[12]។ ការបែងចែករបស់លោកមានតក្កភាព ដើម្បីញែករវាងអ្វីដែលកំណត់ថា វណ្ណយុត្តិ (signes diacritiques) និង ខណ្ឌសញ្ញា (signes de ponctuation)។

តាមពិតទៅ របាទ នៅសម័យមុនអង្គរនិងសម័យអង្គរ មានប្រើហើយ។ ចំពោះវិរាម ក្រោយសម័យអង្គរ គេមិនឃើញមានប្រើទៀតទេ។ ក្នុងករណីមានវិរាមលើ រ គេសម្គាល់ថាព្យាង្គចុងជាព្យាង្គបិទមិនមានសូរស្រៈក្នុងនោះ។ គេមិនអាចសន្និដ្ឋានដោយដាច់ខាតថាសំឡេង រ មិនមាននោះទេ បើទោះបីជាមិនមានវិរាមលើ រ ក្តី។ នាពេលបច្ចុប្បន្ន ការបញ្ចេញសំឡេង រ ចុងពាក្យនៅរក្សាដោយជនជាតិ កួយ និង ខ្មែរនៅខេត្តសុរិន្ទ ជាដើម។ គេអាចនិយាយបានថា នៅសតវត្សរ៍ទី១៩ ប្រជាជននៅបន្លឺសូរ រ ចុងពាក្យនៅឡើយ។

អំឡុងពេលដែលលោកមកបំពេញការងារនៅអាស៊ី បព្វជិតគ្រិស្តសសនា **ហ្សង់-បាបទិស្ត ប៉ាល្លឺហ្គូរ៍** (១៨០៨-១៨៦២), ដែលជាមិត្តភក្តិមួយរូបរបស់ព្រះរាជាសៀម ព្រះចៅ**មង្កុដ** ឬ **រាមាទី៤**, បានកត់សម្គាល់ថាប្រវាស្ត្រខ្មែរនៅរាជធានីឧដុង្គបញ្ចេញសំឡេង រ ដូចអ្នកក្រុងបារីស៍ (“La lettre r est très-fréquente dans leur langue, et ils la prononcent en grasseyant comme les Parisiens ;[13]”)។

ដោយឡែក ចន្ទបាទ, ត្រីសព្ទ, ទណ្ឌឃាត, មូសិកទន្ត, យុគលពិន្ទុ, របាទ, រស្សសញ្ញា, លេខទោ, សំយោគសញ្ញា, លេខអស្តា គេឃើញមានប្រើក្នុងល្បើកនគរវត្ត ៖

- ចន្ទបាទ ក្នុង ដ នៃឃ្លា ឆ្វាក់ជាហដុម៉ានដក្រាបី (ទំ.[៨៥]); ក្នុង មមី បបូរ នៃឃ្លា មុក្ខមាត់មមីបបូរសោះសា (ទំ.[៩៤]);
- ត្រីសព្ទ ក្នុង *កណ្តាលវីហ៊ារ* (ទំ.[៧៧]), *គោហ៊ា* (ទំ.[៨៤]);
- ទណ្ឌឃាត ក្នុង *ដោវរូបអំរឹត្យ៍សំមធ្យ* (ទំ.[៩៦]);
- មូសិកទន្ត ក្នុង *អសដាជ័កាញ៉ា* (ទំ.[៧៣]); *បេទ្វាដាជ័រូបម៉ករ* (ទំ.[៩៥]);
- របាទ ក្នុង *និជ័ចោះឱ្យផែះស្ទួគ៌* (ទំ.[៨៧]); *ដោយព្រាណ៌ាជីឡៃជា១* (ទំ.[៩៦]);
- រស្សសញ្ញា ក្នុង *ខ្ញុំមប្រថ្នាស្រាប់ហោ៎ៀហោជ* (ទំ.[៦៩]);
- សំយោគសញ្ញា ក្នុង *ព្រះវីស្សកម្ម៌* (ទំ.[៧៥]); *វីជាសជាំជ័ពលយក្ខ័យស់* (ទំ.[៨៨]), *ត្រាសប្រើយក្ស័្យ* (ទំ.[៨៦]);
- លេខទោ ក្នុង *ដោយព្រាណ៌ាជីឡៃជា១* (ទំ.[៩៦]);
- លេខអស្តា ក្នុង *ចត្តុរស់ឡៃស៏សវស្តិ៍ម* (ទំ.[៩៥]); ចំពោះសិលាចារឹកនគរវត្ត សញ្ញានេះមាន ដូចក្នុង ថ្វាំថ្លៃយ (IMA ២៧:៤), មេប៉ុក (IMA ៣០:៧២)

---

[12] អៀវ គើស, *ភាសាខ្មែរ ៖ ការល្បងពិនិត្យដោយរកហេតុផល, ភ្នំពេញ, បោះពុម្ពឡើងវិញ, ១៩៩៩*, ទំ.៥៧។

[13] Jean-Baptiste Pallegoix, *Description du royaume Thai ou Siam : La mission de Siam,* Tome premier, (Paris : Lagny, Imprimerie de Vialat et Cie ), 1854, p. 32.

លោក **អៀវ កើស** បញ្ជាក់ថាសម្តេចព្រះសង្ឃរាជ **ជួន ណាត** កាលនៅជាព្រះពោធិវ័ង្ស បានបង្កើតយុគលពិន្ទុ។[14] យើងសង្កេតឃើញ ក្នុងវេយ្យាករណ៍ *មូលកច្ចាយនៈ* របស់សម្តេចព្រះសង្ឃរាជ ភាគទី១ គេមិនឃើញមានប្រើយុគលពិន្ទុទេ ដូចពាក្យ ព្យញ្ជនៈ, វិបនៈ, ស្រៈ ជាដើម។ ក្នុងភាគទី២ លោកចាប់ផ្តើមប្រើយុគលពិន្ទុជាទូទៅ។[15] គួរកត់សម្គាល់បន្ថែមថា សេចក្តីសម្រាយក្នុងព្រះត្រៃបិដកជាភាសាខ្មែរ ដែលនៅផ្នែកខាងស្តាំនោះ អ្នករៀបរៀបនិងបកប្រែបានប្រើយុគលពិន្ទុជាទូទៅចំពោះពាក្យដែលមានសូរ អាក់ ខាងចុង ហើយ មិនបន្តភ្ជាប់ដោយពាក្យមួយទៀត។

ទោះយ៉ាងណាក្តី យុគលពិន្ទុ យើងឃើញមានបញ្ជាក់ក្នុងវេយ្យាករណ៍លោក **ម៉ាស្ប៉េរ៉ូ** ត្រង់ចំណុចស្រៈនិងស្រៈផ្សំ ដែលសញ្ញា «ៈ» ត្រូវបានប្រើសម្រាប់សម្គាល់ស្រៈខ្លី ទាំងខាងពួកអទាំងខាងពួកអ៊។ លោកបង្ហាញចំណុចនេះក្នុងន័យលក្ខណៈដោយឧទាហរណ៍ ៖ ស្រៈ s̲ră, pāli *saro,* sc. *svara*។[16]

តាមលោក **ម៉ាស្ប៉េរ៉ូ** ការកែប្រែដោយយក សម្លាប់ ឬ ធ្មេញកណ្តុរ ប្រើជំនួសសក់ក ឬ ត្រីសព្ទ ដើម្បីសម្គាល់សូរអ៊ ជាការកែប្រែថ្មី។[17] គួរកត់សម្គាល់ថាការប្រើសញ្ញាគូសពីរពីក្រោមព្យញ្ជនៈមកដល់ពេលដែលលោក **ម៉ាស្ប៉េរ៉ូ** សរសេរសៀវភៅនោះត្រូវបានគេប្រើសម្រាប់ប្តូរសូរពីពួកអទៅពួកអ៊ ពីពួកអ៊ទៅពួកអ។ ជាឧទាហរណ៍ សូរអ គេសរសេរ អ អា អែ អោ, សម្រាប់សូរអ៊ គេសរសេរ អ៊ អ៊ែ ជាដើម។ អ៊ែ នេះមានសង្កត់ (សញ្ញាគូសពីរពីក្រោមតួអ)។[18]

អក្សរនៅសម័យកណ្តាលមានសញ្ញាមួយចំនួនដែលអ្នកស្រាវជ្រាវពិបាកប្រើតាងដោយអក្សរឡាតាំង ដូចជា ចន្ទបាទ (សញ្ញាគូសពីរពីក្រោម), លេខបូក (+), អស្តា (៨)។ គួរបញ្ជាក់ត្រង់ចំណុចនេះផងដែរថាជើង ដ នៅសម័យកណ្តាលមានប្រើហើយ ដូចមានក្នុងសិលាចារឹកនគរវត្តលេខ១និងលេខ១៩ជាឧទាហរណ៍[19]។

---

[14] អៀវ កើស, *-ជ.ឯ.ម..-*, ទំ.៥៣។

[15] *កច្ចាយនូបត្ថម្ភ* នេះ សម្តេចព្រះសង្ឃរាជរៀបចំចប់សព្វគ្រប់នៅឆ្នាំ១៩៣២។ ឯកសាររបស់លោកដែលបន្សល់ដល់សព្វថ្ងៃ ភាគទី១បោះពុម្ពចុងក្រោយឆ្នាំ១៩៥១ គ្រាទី ៥, ភាគទី២បោះពុម្ពឆ្នាំ១៩៦២ គ្រាទី៦។
តាមសម្តេចព្រះសង្ឃរាជ **ហួត តាត** កិច្ចការដែលសម្តេចព្រះសង្ឃរាជ **ជួន ណាត** សព្វព្រះទ័យធ្វើបន្តក្រៅពីវចនានុក្រម គឺ *វេយ្យាករណ៍ខ្មែរ* និង *វេយ្យាករណ៍បាលី* (សម្រាប់រៀនឆាប់យល់)។ក្រៅពីនេះ ទ្រង់ក៏មានព្រះរាជបំណងនិពន្ធឱ្យពិស្តារសៀវភៅ *បព្វជាខន្ធកៈ* និង *សីមាវិនិច្ឆ័យ*។(ហួត តាត, *កល្យាណមិត្តរបស់ខ្ញុំ*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ទំ.៦៣។)

[16] Maspero, *Grammaire de la langue khmère,* (Paris : Imprimerie nationale, 1915), p. 53.

[17] *Ibid.,* p. 73.

[18] *Ibid.*, p. 153.

[19] នៅអំឡុងឆ្នាំ២០០៨ គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាននៃគណៈកម្មាធិការជាតិភាសាខ្មែរ, មុនក្លាយជាក្រុមប្រឹក្សាជាតិភាសាខ្មែរក្នុងឆ្នាំ២០១១, បានលើកគំនិតទាក់ទងការបង្កើតសញ្ញាជើង ដ។ តាមគំនិតសមាជិកក្នុងគណៈកម្មការ ជាពិសេស គំនិតលើកដោយលោក **ថាច់ សែម** (១៩៣៤-២០២១) ឯកឧត្តម **ឈន អៀម** និង ឯកឧត្តម **សូ មុយឃៀង** ជើង ដ គេអាចកួចសងខាង ឬ កួចតែខាងស្តាំ។នៅខែតុលាឆ្នាំ២០២៣ បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** អតីតប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានស្នើប្រជុំជាមួយនឹងបណ្ឌិត **ហ៊ាន សុខុម** ប្រធានក្រុមប្រឹក្សាភាសាជាតិថ្មី និង អ្នកស្រាវជ្រាវនៅវិទ្យាស្ថានភាសាជាតិនិងក្រុមប្រឹក្សាជាតិភាសាខ្មែរទាក់ទងនឹងសម្នើរបស់លោកបណ្ឌិតសភាចារ្យឱ្យពិចារណាដើម្បីបង្កើតរូបជើង ដ ឱ្យផ្សេងពីជើង ត។គួរបញ្ជាក់ថា ក្រៅពីសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ លោក **ថាច់ សែម** (១៩៣៤-២០២១) ជាអ្នកភាសាបាឡីមួយរូប និង ជាអ្នកកែអក្ខរាវិរុទ្ធនៅទីស្តីការគណៈរដ្ឋមន្ត្រី។ មុននឹងទទួលតំណែងចុងក្រោយជាទីប្រឹក្សាអមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ លោកជាអតីតប្រធាននាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។លោក **ធន់ ហ៊ិន** (១៩៤៥-២០១៩) ជាអ្នកនិពន្ធមួយរូបចេះភាសាច្រើន ដូចជា ភាសាបារាំង អង់គ្លេស អេស្ប៉ាញ និង ព័រទុយហ្កាល់។ ស្នាដៃមួយចំនួនរបស់លោកមាន ដូចជា *ទស្សនវិជ្ជានៃអភិសមាចារ* (២០០៦), *រាមាយណៈ* (៩ភាគ, ២០០៥) , *រាជសព្ទក្នុងភាសាខ្មែរ* (២០០១), *វេយ្យាករណ៍ខ្មែរ* (២០១១) ជាដើម។ ស្នាដៃចុងក្រោយរបស់លោក គឺ *មហាភារតៈ* (២០១៨)។លោក **មៀច ប៊ុណ្ណ** (១៩៣២-

លោក **អៀវ កើស** បានបង្ហាញពីប្រវត្តិវណ្ណវត្តិខ្មែរមួយចំនួនដែលបានមកពីលេខអត្ថៈបែបក្បួនហោរាខ្មែរ ៖ លេខ១ លេខឯកឬអឌ្ឍចន្ទ ប្រើសម្រាប់បញ្ជាក់ស្រៈ ដូចជាប្រើលើ រ ក្នុង រងា, ប្រើលើ ត ក្នុង តមក និង លើ បទីពីរក្នុង បបរ ជាដើម។; លេខ២ លេខទោ, លេខ៣ ត្រីស័ព្ទ; ចុងលេខ៥ លើបាំងឈើជា ែ; លេខ៦ លើបាំងឈើជា ៃ; លេខ៧ សប្ត ប្រើលើស្រៈអេឱ្យក្លាយសូរអឺ ដូចជាប្រើលើពាក្យ ម ក្នុង មេង > មឹង; លេខ៨ អស្តា; លេខ៩ ទណ្ឌឃាត; លេខសូន្យ និគ្គហិត។ បណ្តាសញ្ញាទាំងនេះ លេខឯក និង លេខសប្ត មិនឃើញប្រើនាពេលបច្ចុប្បន្នទេ។[20]

នៅក្រោយការដំណើរការការងាររបស់ក្រុមជំនុំធ្វើវចនានុក្រមខ្មែរនាឆ្នាំ១៩១៥ប្រហែលដប់ឆ្នាំ គណៈកម្មការនេះបានលើកគំនិតកំណែទម្រង់ពក្នុងភាសាខ្មែរ។ ទីមួយ ការមិនប្រើសញ្ញា “សង្កត់” ឬ “ក្បៀស” (បន្តក់) ; ទីពីរ ការប្រើ“សំយោគសញ្ញា”ជំនួសបន្តក់ ឬ មិនប្រើតែម្តង; ទីបី ការប្រើសញ្ញាអឌ្ឍចន្ទ។

ជាឧទាហរណ៍ត្រង់ចំណុចទីពីរនិងទីបី កក ដែលប្រើសញ្ញាអឌ្ឍចន្ទលើតួទីមួយហើយ តួទីពីរត្រូវបានសម្គាល់ថាព្យាង្គចុងជាសូរប្រកបវែង ដូចក្នុងពាក្យ កក; ឯពាក្យ កក ដែលមិនមានប្រើសញ្ញាអឌ្ឍចន្ទលើទីតួទីមួយត្រូវបានសម្គាល់ថាព្យាង្គខាងចុងជាសូរប្រកបខ្លី ដូចក្នុង កក់។ ចំពោះសំយោគសញ្ញា គេប្រើវាដើម្បីសម្គាល់ព្យាង្គខ្លីចំពោះពាក្យដូចជា កាក > ក័ក។[21]

## ២. ការប្រើអក្សរឡាតាំងតាងអក្សរខ្មែរ

លោកស្រី **ពៅ សាវរស** (១៩២៩-២០២០) បានកត់សម្គាល់ថាអ្នកសិក្សាភាសាខ្មែរដំបូងបានយកអក្សរឡាតាំងសម្រាប់ភាសាសំស្ក្រឹតមកប្រើក្នុងភាសាខ្មែរពីព្រោះប្រព័ន្ធសញ្ញាភាសាខ្មែរចាស់មានតម្លៃដូចគ្នានឹងប្រព័ន្ធសំស្ក្រឹត (un système de signes équivalant au système sanskrit)។ គេប្រើអក្ខរវិធីសំណងនេះសម្រាប់សិក្សាសិលាចារឹកពីសតវត្សរ៍

២០១២) ជាអ្នកនិពន្ធប្រពៃណីទំនៀមទម្លាប់នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ ស្នាដៃចុងក្រោយរបស់លោក គឺ *កម្រងឯកសារ ស្តីពី ប្រពៃណី និង ទំនៀមទម្លាប់ខ្មែរ* ភាគ ៤ បោះពុម្ពឆ្នាំ២០១១។បណ្ឌិតសភាចារ្យ **អ៊ឹរ ច័ន** (១៩៤២-២០១៣) សរសេរនិក្ខេបបទ *ប្រវត្តិសង្គម-វប្បធម៌នៃប្រទេសកម្ពុជានាសតវត្សរ៍ទី១៩* (ភាសារុស្ស៊ី) ឆ្នាំ១៩៩២។ ក្រៅពីការងារបង្រៀននិងការងារដឹកនាំនិក្ខេបទ លោកជាប្រធានវិទ្យាស្ថានភាសាជាតិ (២០០៧-២០១៣) និង ជាអនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ (២០១១-២០១៣)។ខាងផ្នែកស្រាវជ្រាវ លោកជានិពន្ធនាយករង *វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ* ឆ្នាំ២០០៥និង ជានិពន្ធនាយកនៃ *វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ* ឆ្នាំ២០១៧។ – គួររំឭកដោយខ្លីត្រង់នេះថាបណ្ឌិតសភាចារ្យ **ឡុង សៀម** (១៩៣៥-២០០៧) ជាប្រធានដំបូងនៃវិទ្យាស្ថានភាសាជាតិ និង ជានិពន្ធនាយក *វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ* ឆ្នាំ២០០៥។លោកក៏ជាប្រធានដំបូងនៃគណៈកម្មាធិការជាតិភាសាខ្មែរដែរ។តាមព្រះរាជក្រឹត្យចុះថ្ងៃ១៥សីហាឆ្នាំ២០១១ ឯកឧត្តមបណ្ឌិត **ម៉ៅ សុក្កន** ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ឹរ ច័ន** ឯកឧត្តម **ឈន អៀម** ឯកឧត្តម **សូ មុយឃៀង** ឯកឧត្តម **ម៉ៅ សុក្កន** លោក **សឹង ផុស** និង លោក **ធន់ ហ៊ិន** ទទួលការតែងតាំងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលមានឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** ជាប្រធាន។ ក្នុងព្រះរាជក្រឹត្យឆ្នាំ២០១៣ លោកបណ្ឌិត **ម៉ៅ សុក្កន** (១៩៤៦-២០២១) ត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការ ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី។ ក្នុងសេចក្តីសម្រេចថ្ងៃទី២២ខែវិច្ឆិកាឆ្នាំ២០១៧ស្តីពីបង្កើតគណៈកម្មការបច្ចេកទេសរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ឯកឧត្តមបណ្ឌិត **ម៉ៅ សុក្កន** និង លោក **សឹង ផុស** ជាសមាជិកគណៈកម្មការភាសាវិទ្យា។ឯកឧត្តម **ឈន អៀម** ឯកឧត្តម **សូ មុយឃៀង** និង លោក **ថាច់ សែម** នៅបន្តជាសមាជិកគណៈកម្មការអក្ខរាវិរុទ្ធ។

[20] អៀវ កើស, *-ដ.ឯ.ម.-*, ទំ.៥៥, ន័យលក្ខណៈលេខ១។

[21] Cf. Georges Cœdès, “Dictionnaire cambodgien.” Tome I, K-M. In: *Bulletin de l'Ecole française d'Extrême-Orient*. Tome 38, 1938, p. 317.

ទី៧ដល់ទី១៤។ ប៉ុន្តែ ប្រព័ន្ធសញ្ញានេះត្រូវប្រែប្រួលក្នុងការកត់ឯកតាសូរ (unités phoniques) ក្នុងអំឡុងចាប់ពីសតវត្សរ៍ទី១៥រៀងមក។ ដូច្នេះ គេត្រូវប្រើវណ្ណយុត្ត (diacritiques) បន្ថែមលើអក្សរឡាតាំងដែលសងអក្សរខ្មែរនោះ។[22]

គេអាចនិយាយបានថាលោក **ល្វី ហ្វីណូត៍**[23] (១៨៦៤-១៩៣៥) ជាអ្នកស្រាវជ្រាវដំបូងដែលយកអក្សរឡាតាំងមកកត់សងអក្សរខ្មែរ។ លោកកត់សម្គាល់រវាងសូរស្ទះផ្ទុះ, ដោយលើកលែងសូរមុទ្ធជៈ (ឡ), ត្រូវនឹងសូរផ្ទុះថ្លង់។ បំណែងចែកនេះនាំឱ្យគេអាចបំបែកអក្សរជាបានព្យញ្ជនៈពួក អ និង ព្យញ្ជនៈពួក អ៊ ពីព្រោះសូរថ្លង់ក្នុងភាសាសំស្ក្រឹតត្រូវគ្នានឹងស្រៈកប់ អ ឯសូរស្ទះសំស្ក្រឹតត្រូវនឹងសូរកប់ អ៊។

លោក **ហ្វីណូត៍** កត់សម្គាល់បន្តថាមិនមែនតែសូរស្រៈកប់នេះពួក (series) ព្យញ្ជនៈនោះទេ តែ វាក៏បែងចែកស្រៈដែរ។ នៅប៉ែកខាងចុងនៃអត្ថបទ លោកបានប្រើ h សម្រាប់វិសគ៌ៈ និង ស សម្រាប់ធនិត (aspiration)។

អក្ខរវិធីសំណងរបស់លោក **ហ្វីណូត៍** ត្រូវបានធ្វើវិវេចនាដោយលោក **ណរបែត៍-ម៉ូរីស ហ្វូរស្ទីយេរ**[24]។ លោក **ហ្វីណូត៍** បានបញ្ជាក់តបថាសញ្ញា ៊ ៉ នេះកើតឡើងសម័យថ្មីនិងមានប្រភពពីសៀម។ លោក **ហ្វូរីស្ទីយេរ** ជឿជាក់ថារឿងនេះកើតនៅដើមសតវត្សរ៍ទី១៩ ប៉ុន្តែ លោក **ហ្វីណូត៍** យល់ថាសញ្ញានេះអាចកើតមុននេះ ហើយ ថាសម្តេចព្រះសុគន្ធាធិបតី **ប៉ាន** (១៨២៤-១៨៩៤) អាចជាអ្នកបង្កើតសញ្ញាស្រៈ។ ទាក់ទងនឹងសម្តេច **ប៉ាន** លោក **ហង្រ៊ុក ម៉ាស្ពេរ៉ូ** (១៨៧២-១៩៤២) យល់ថាទ្រង់ជាអ្នកកំណត់តម្លៃថ្មីដល់ ដ ក្នុងព្យញ្ជនៈខ្មែរ[25] ហើយ មុននេះ គេបានប្រើ ត សម្គាល់សូរ ដ ដែរ ដូចក្នុងពាក្យ តំម្រី ជាដើម ដែលលោកបានស្រង់ពីសិលាចារឹកនគរវត្ត[26]។

ដោយសិក្សាឈ្មោះភូមិឃុំស្រុកខេត្តខណ្ឌក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន[27] យើងបានស្រង់និងសម្រួលអក្សរឡាតាំងប្រើតាងអក្សរខ្មែរ។ យើងបានចែកក្រុមព្យញ្ជនៈនិងស្រៈ។ ចំណុចខ្វះខាតនៃអក្សរឡាតាំងដែលយើងបានស្រង់ទាំងនេះមានដូចជា ស្រៈមួយចំនួនត្រូវតាងដោយអក្សរឡាតាំងតែមួយ ៖ អ, អា តាងដោយ a, អុ អូ តាងដោយ o, អ៊ុ អ៊ូ តាងដោយ u, អឺ អ៊ឺ តាងដោយ eu។ ចំណុចវិជ្ជមាននៃអក្សរឡាតាំងដែលស្នើឡើងនេះសម្រួលដល់ការប្រើសញ្ញាច្រើននិងស្មុគស្មាញ។ ទោះសរសេរក្នុងប្រព័ន្ធអេឡិចត្រូនិកក្តីក្នុងសំណេរដៃលើផ្ទាំងក្រដាសអ្វីក្តី អ្នកប្រើប្រាស់មិនចាំ

---

[22] Saveros Lewitz, "Note sur la translitération du cambodgien", In: *Bulletin de l'Ecole française d'Extrême-Orient.* Tome 55, 1969. p. 163.

[23] លោកជាគ្រូម្នាក់ដែលបង្រៀនវិជ្ជាភាសាសំស្ក្រឹតដល់សម្តេចព្រះសង្ឃរាជ **ជួន ណាត** និង សម្តេចព្រះសង្ឃរាជ **ហួត តាត** កាលព្រះអង្គទាំងពីរនិមន្តទៅសិក្សានៅទីក្រុងហាណូយ ឆ្នាំ១៩២២។

[24] លោកជារេស៊ីដង់ត៍រង និង ជាប្រធាន Bureau des roles et de l'immigration ដែលជាការិយាល័យមួយនៃការិយាល័យនានាស្ថិតក្រោមចំណុះនៃរេស៊ីដង់ត៍ ស៊ុប៉េរីយ៉េរ ដែលមានលោក Albert-Louis Huyn de Vernéville (**១៨៤៥-១៩០៩**) កាន់ការតាំងពីឆ្នាំ១៨៩៤មក។

[25] Maspero, *op.cit*,, p. 119.

[26] លោក **ម៉ាស្ពេរ៉ូ** សរសេរក្នុងសៀវភៅលោក តំម្រី តែក្នុងសិលាចារឹកនគរវត្តលេខ ៣៨ មានតែ តំម្រិ្យ (ប.៤៩), តំរិ្យ (ប.៥២)។ ទោះយ៉ាងណាក្តី ក្នុងសិលាចារឹកនេះ គេក៏ឃើញមានប្រើអក្សរ ដ ដែរ ដូចក្នុង ត្រៃបីដក (ប.៦)។ ទោះយ៉ាងណាក្តី ដ មានតម្លៃសញ្ញាផ្ទាល់ខ្លួនហើយនៅសតវត្សរ៍ទី១៧ ដូចមានក្នុងល្បើកអង្គរវត្ត ៖ ក៏ស្តេចដើរទេសពន្លឺបរ (ទំ.[៨២]), ម៉មីដាប់ដាល់ ក៏កាន់ដំបងផ្ការងរ (ទំ.[៨៨]), ប្រាំម្យូជិន្តប់ (ទំ.[៩២]), ...។ គំនិតពីក្រុមជំនុំវចនានុក្រមខ្មែរគ្រាទី៤មកគ្រាទី៥មានរង្វាតគ្នាដោយការសម្រួលទៅរកសនិទានភាពនិងវេយ្យាករណភាព។ ក្នុងផ្នែក ដ នៅគ្រាបោះពុម្ពដំបូងឆ្នាំ១៩៣៨ អក្ខរាវិទ្ធអាចសរសេរពីរបែប បីបែប ឬ បួនបែប។ ឧទាហរណ៍ ៖ ដំណែង ឬ តំណែង, ដំបារ ឬ ដម្បារ, ដំបូក ឬ ដម្បូក; ដំរួត, ដម្រួត ឬ តម្រួត, ដំឡង់, ដម្លង់ ឬ តម្លង់; ដំរា, ដម្រា ឬ តំរា, តម្រា; ដំរិះ, ដម្រិះ ឬ តំរិះ, តម្រិះ។

[27] លោកស្រីបណ្ឌិត **ហង់ ថាវី** កំពុងសិក្សាឈ្មោះរដ្ឋបាលដែនដីខ្មែរនាសម័យបច្ចុប្បន្ន។

បាច់ប្រើសញ្ញាពិសេសពិសេសរកនិងពិបាកចាំ។ ម្យ៉ាងទៀត, ក្រៅពីអ្នកបច្ចេកទេសនិងអ្នកស្រាវជ្រាវ, គេមិនចាំបាច់ប្រើសញ្ញាសព្ទគ្រប់លើអក្សរឡាតាំងដើម្បីឱ្យសងអក្សរឱ្យសព្ទគ្រប់នោះដែរ៕[28]

| លស. | ព្យញ្ជនៈ | | ជើងព្យញ្ជនៈ | | អក្សរឡាតាំង |
|---|---|---|---|---|---|
| | *ពួកអ* | *ពួកអ៊ិ* | *ពួកអ* | *ពួកអ៊ិ* | |
| ១ | ក | គ | ្ក | ្គ | k |
| ២ | ខ | ឃ | ្ខ | ្ឃ | kh |
| ៣ | (ង៉) | ង | ្ង | ្ង | ng |
| ៤ | ច | ជ | ្ច | ្ជ | ch |
| ៥ | ឆ | ឈ | ្ឆ | ្ឈ | chh |
| ៦ | (ញ៉) | ញ | ្ញ | ្ញ | nh |
| ៧ | ដ | ឌ | ្ដ | ្ឌ | d |
| ៨ | ឋ | ឍ | ្ឋ | ្ឍ | th |
| ៩ | ថ | ធ | ្ថ | ្ធ | th |
| ១០ | ណ | ន | ្ណ | ្ន | n |
| ១១ | ត | ទ | ្ត | ្ទ | t |
| ១២ | ប | (ប៊) | ្ប | ្ប | b |
| ១៣ | ផ | ភ | ្ផ | ្ភ | ph |
| ១៤ | (ប៉) | ព | ្ប | ្ព | p |
| ១៥ | (ម៉) | ម | ្ម | ្ម | m |
| ១៦ | (យ៉) | យ | ្យ | ្យ | y |
| ១៧ | (រ៉) | រ | ្រ | ្រ | r |
| ១៨ | ឡ | ល | ្ល | ្ល | l |
| ១៩ | (វ៉) | វ | ្វ | ្វ | v |
| ២០ | ស | (ស៊) | ្ស | ្ស | s |
| ២១ | ហ | (ហ៊) | ្ហ | ្ហ | h |
| ២២ | អ | (អ៊) | ្អ | ្អ | ’ |

[28] យើងបានភ្ជាប់ឯកសារទាក់ទងនឹងភាសាខ្មែរ ជាពិសេស ទាក់ទងនឹងអក្ខរាវិធីសំណង់ជាអក្សរឡាតាំងក្នុងឧបសម្ព័ន្ធតាមលំដាប់ផ្នាំ។

*កំណត់សម្គាល់ ៖*

- អក្សរក្នុងវង់ក្រចកមិនមានក្នុងលំដាប់នៃទម្លាប់រាប់ព្យញ្ជនៈនៃភាសាខ្មែរទេ។   យើងបំពេញនេះដើម្បីតម្រូវបំពេញអក្សរទៅប្រភេទពួកអអ៊ិ ដូចដែលមានក្នុងការប្រើប្រាស់ជាក់ស្តែង។
- ញមានជើងតម្រួតពីរ ដូចក្នុងពាក្យ ផ្ញើ ស្ញើប ជាដើម និង ដូចក្នុងពាក្យ បញ្ញត្ត បញ្ញើ ជាដើម។

| ល.រ. | ស្រះ | | អក្សរឡាតាំង | |
|---|---|---|---|---|
| | *ពួកអ* | *ពួកអ៊ិ* | *ពួកអ* | *ពួកអ៊ិ* |
| ១ | I, ◌់ | (II), ◌់ | a | o |
| ២ | ◌ា◌់, ◌័ | ◌ា◌់, ◌័ | a | ea |
| ៣ | ◌ិ | ◌ិ | e | i |
| ៤ | ◌ី, ឦ | ◌ី, ◌៊◌ី, ◌ី◌ុ, ឦ | ei | i |
| ៥ | ◌ឹ | ◌៊◌ឹ, ◌ឹ◌ុ | oe | ue |
| ៦ | ◌ឺ | ◌ឺ | oe | ue |
| ៧ | ◌ុ, ឧ | ◌ុ, ឧ | o | u |
| ៨ | ◌ូ, ឩ | ◌ូ, ឩ | o | u |
| ៩ | ◌ួ | ◌ួ | uo | uo |
| ១០ | ◌ើ | ◌ើ | aeu | eu |
| ១១ | ◌ឿ | ◌ឿ | oea | oea |
| ១២ | ◌ៀ | ◌ៀ | ie | ie |
| ១៣ | ◌េ, ឯ | ◌េ, ឯ | e | e |
| ១៤ | ◌ែ, ឯ | ◌ែ, ឯ | ae | eae |
| ១៥ | ◌ៃ, ឰ | ◌ៃ | ai | ey |
| ១៦ | ◌ោ, ឱ | ◌ោ | ao | ou |
| ១៧ | ◌ៅ, ឪ/ឳ | ◌ៅ, ឪ | au | ov |
| ១៨ | ◌ំ◌ុ | ◌ំ◌ុ | om | um |
| ១៩ | ◌ំ | ◌ំ | am | om |
| ២០ | ◌ាំ | ◌ាំ | am | oam |
| ២១ | ◌ះ | ◌ះ | ah | eah |

*កំណត់សម្គាល់ ៖*

- សញ្ញា ॥ ក្នុងវង់ក្រចកមិនមានក្នុងសញ្ញាស្រៈនៃភាសាខ្មែរ, មានតែសញ្ញា । ទេ។ សញ្ញាគូស । នេះទៀតសោតមានតម្លៃច្រើនខាងផ្នែកគរុកោសល្យដើម្បីបង្ហាញសូរស្រៈអ ប៉ុន្តែ នៅពេលសរសេរចេញជាព្យាង្គ ក ខ ជាដើម សញ្ញានេះមិនបង្ហាញជារូបទៀតទេ។ យើងស្នើប្រើសញ្ញាគូស ॥ ដើម្បីបង្ហាញសូរស្រៈ អ៊។
- អក្សរឡាតាំង i តាងស្រៈអ៊ិផង ស្រៈអ៊ីផង, អក្សរឡាតាំង e តាងស្រៈអេផង ស្រៈអ៊េផង, អក្សរឡាតាំង oe តាងស្រៈអឹផង ស្រៈអឺផង ហើយ ue តាងស្រៈអ៊ឹ ផង ស្រៈអ៊ឺផង, អក្សរឡាតាំង oea តាងស្រៈអឿផង អ៊ឿផង។
- ស្រៈពេញ ឧ ឩ នេះមិនប្រាកដសូរទេ។ ទោះបីស្មើរតែទាំងអស់មានសូរ អ៊ ក្តី ក៏ពាក្យខ្លះមានសូរ អ ដូចជា ឧស ឬ អុស, ឧដ្ឋ ឬ អូដ្ឋ, ឩន ឬ អួន ជាដើម។
- សញ្ញា ' ប្រើសម្រាប់សម្គាល់សូរអក្នុងបន្សំជាព្យញ្ជនៈទីពីរ ដូចជា k'am (ក្អម), k'aek (ក្អែក) ជាដើម៕

កែវ លីណែត

*ប្រធាននាយកដ្ឋាន ខេមរនីយកម្ម វចនានុក្រម និង បកប្រែ*
*វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា*

## គន្ថនិទ្ទេស (សម្រាំង)


### សៀវភៅនិងអត្ថបទ

ជួន ណាត, *កច្ចាយនូបត្ថម្ភ*, ភ្នំពេញ, ការផ្សាយរបស់ក្រសួងធម្មការ, ភាគ១ គ្រាទី៥ ១៩៥១, ភាគ២ គ្រាទី៦ ១៩៦២។

___, *ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត*, ភ្នំពេញ, ១៩៧០។

នរោត្តម សីហនុ, *អនុស្សាវរីយ៍ផ្អែមល្ហែម និង ជូរចត់*, បកប្រែដោយ នរោត្តម រណឫទ្ធិ, ១៩៨០។

ប៉ុណចន្ទ ម៉ុល, *គុកនយោបាយ*, ភ្នំពេញ, ១៩៧១។

មាស, *រឿងបន្ទាំមតាមាស*, ១៩០៧។

ប៉ង, *ល្បើកអង្គរវត្ត*, សុខា ធូម និង ហាម ឆាយលី លំនាំដើម, ភ្នំពេញ, គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ, ២០០៩។

ឈឹម ក្រសេម, ហ្សកែ សីដែស, *សិលាចារឹកនគរវត្ត*, Paris : មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ/Centre de Documentation et de Recherche sur la Civilisation Khmère, ១៩៨៤។

សេ អឿន, *ពាក្យកម្ចីសំស្ក្រឹត-បាលីក្នុងភាសាខ្មែរទំនើប*, បរិញ្ញាបត្រជាន់ខ្ពស់, រាជបណ្ឌិត្យសភាកម្ពុជា, ២០០២។

ហួត តាត, *កល្យាណមិត្តរបស់ខ្ញុំ*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ។

អៀវ កើស, *ភាសាខ្មែរ ៖ ការល្បងពិនិត្យដោយរកហេតុផល*, ភ្នំពេញ, បោះពុម្ពឡើងវិញ, ១៩៩៥។

Cœdès, Georges. "Dictionnaire cambodgien." Tome I, K-M. In: *Bulletin de l'Ecole française d'Extrême-Orient.* Tome 38, 1938;

Finot, Louis. "Notre transcription du Cambodgien." In: *Bulletin de l'Ecole française d'Extrême-Orient.* Tome 2, 1902. pp. 1-15;

Gordon, Henri. *Enseignements des indigènes en indochine,* (Paris : Société Générale d'imprimerie et d'édition levé, 1910;

Jean-Baptiste Pallegoix, *Description du royaume Thai ou Siam : La mission de Siam,* Tome premier, (Paris : Lagny, Imprimerie de Vialat et Cie ), 1854;

Maspero, Georges. *Grammaire de la langue khmère (cambodgien).* Paris: Imprimerie Nationale, 1915;

Sarason, Seymour B. Political Leadership and Educational Failure, California: Jossey-Bass Inc., Publishers, 1998);

Saveros Lewitz. "Note sur la translittération du cambodgien." In: *Bulletin de l'Ecole française d'Extrême-Orient.* Tome 55, 1969. pp. 163-169.

### វចនានុក្រម

នួន ប៊ុត, *វចនានុក្រមខ្មែរ*, ភ្នំពេញ, បណ្ណាគារ ប៊ុត នាង, ១៩៥៤។

*វចនានុក្រមខ្មែរ*, ក្រោមការដឹកនាំរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧-៦៨។

*វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ*, វិទ្យាស្ថានភាសាជាតិ, ២០១៧។

*វចនានុក្រមភាសាខ្មែរ*, ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០២២។

ឡុង សៀម, *វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦-៨)*, ភ្នំពេញ, រោងពុម្ពភ្នំពេញ, ២០០០។

Crawfurd, John. *Grammar and Dictionary of the Malay Language*. London: Smith, Elder, and Co., 1852.

Echols, John M. and Hassan Shadlily. *And Indonesian-English Dictionary*. 2nd ed. Ithaca and London: Cornell University Press, 1960.

Jenner, Philip N. *A Dictionary of Middle Khmer*. Bangkok: Amarin Printing Company Ltd., 2011.

Pou Saveros. *Dictionnair vieux-khmer-français-anglais/An Old Khmer-French-English Dictionary/វចនានុក្រមខ្មែរចាស់-បារាំង-អង្លេស*, Paris: មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ/Centre de Documentation et de Recherche sur la Civilisation Khmère, 1992.

Rhodes, Alexandre de. *Dictionarium Annamiticum Lusitanum et Latinum*. [វចនានុក្រមអណ្ណាម-ព័រទុយហ្គេស៍-ឡាតាំង]. 1651.

Santos, Vito C. & Santos, Luningning E. *New Vicassan's English-Pilipino dictionary*. Manila: Vito C. Santos & Luningning E. Santos, 1995.

Stevens, Alan M. and A. Ed. Schmidgall-Tellings. *A Comprehensive Indonesian-English Dictionary*. 2nd ed. Athens: Ohio University Press, 2010.

## <u>គេហទំព័រ</u>

- https://vi.wikipedia.org/wiki/Danh_s%C3%A1ch_C%C3%B4ng_s%E1%BB%A9_Ph%C3%A1p_t%E1%BA%A1i_%C4%90%C3%B4ng_D%C6%B0%C6%A1ng
- https://vamospanish.com/discover/the-spanish-influence-on-filipino-culture-and-language/ #:~:text=Spain's%20colonization%20of%20the%20Philippines,Tagalog%20words%20 originating%20from%20Spanish. (១៨.១២.២៣)
- https://linguistics.byu.edu/classes/Ling450ch/reports/bahasa.htm (១៨.១២.២៣)
- https://en.wikibooks.org/wiki/Dutch_Empire/Language (១៨.១២.២៣)

# ឧបសម្ព័ន្ធ

កំណត់សម្គាល់ ៖ យើងរៀបឯកសារតាមលំដាប់ឆ្នាំ។ ធ្វើបែបនេះ យើងគិតថាវាអាចជាការងាយដល់អ្នកស្រាវជ្រាវដើម្បីតាមដានការវិវត្តគំនិតនិងដំណើរការងារទាក់ទងផ្ទាល់ឬប្រយោលលើបញ្ហាអក្ខរវិធីសំណងរបស់ភាសាខ្មែរ។ បន្ទាប់ពីឯកសារ យើងបានភ្ជាប់រូបអនុស្សាវរីយ៍ខ្លះក្នុងដំណើរការងារទាក់ទងភាសាខ្មែរ។


- Finot, Louis. "Notre transcription du Cambodgien." In: *Bulletin de l'Ecole française d'Extrême-Orient. Tome 2, 1902*. pp. 1-15;
- Cœdès, Georges. "Dictionnaire cambodgien." Tome I, K-M. In: *Bulletin de l'Ecole française d'Extrême-Orient.* Tome 38, 1938. pp. 314-321;
- Lewitz Saveros. "Note sur la translittération du cambodgien." In: *Bulletin de l'Ecole française d'Extrême-Orient.* Tome 55, 1969. pp. 163-169;
- *Romanization of Khmer (Cambodian) BGN/PCGN 1972*;
- *Geographical Names of the Kingdom- of Cambodia,* Reports by Governments on the Situation in Their Countries and on the Progress Made in the Standardization of Geographical Names since the Seventh Conference, Eighth United Nations Conference on the Standardization of Geographical Names, Berlin, 27 August - 5 September 2002;
- Ith Sotha, Chharom Chin, Narith Ro, MLMUPC, *Current Status of the Standardization of Geographical Names in Cambodia;* Regional Training Programme in Toponymy, including Marine Toponymy, 19 to 24 March 2018, Manila, the Philippines;
- ឃឹម វិច្ឆិកា, "ទិដ្ឋភាពទូទៅនៃភាសាខ្មែរក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ (ករណី : ការកត់សូរភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរ)", *ព្រឹត្តិបត្រក្រុមប្រឹក្សាជាតិភាសាខ្មែរ*, លេខ១១, ២០២០, ទំ.១១៦-១៣០។
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ ឆ្នាំ២០០៧
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ឆ្នាំ២០១៧

Bulletin de l'Ecole française d'Extrême-Orient

# Notre transcription du Cambodgien

L. Finot

**Citer ce document / Cite this document :**

Finot L. Notre transcription du Cambodgien. In: Bulletin de l'Ecole française d'Extrême-Orient. Tome 2, 1902. pp. 1-15;

doi : https://doi.org/10.3406/befeo.1902.1094

https://www.persee.fr/doc/befeo_0336-1519_1902_num_2_1_1094

Fichier pdf généré le 07/02/2019

# NOTRE TRANSCRIPTION DU CAMBODGIEN

Par M. L. FINOT

*Directeur de l'Ecole Française d'Extrême-Orient*

On discute depuis longtemps sur le meilleur mode de noter en lettres latines les mots de la langue cambodgienne, sans qu'on ait réussi jusqu'à présent à tomber d'accord, non seulement sur les détails, mais sur le principe même de cette notation. En abordant de nouveau cette question épineuse, nous n'espérons pas un meilleur succès que nos devanciers; mais, comme il est nécessaire d'adopter un système uniforme pour les travaux de l'Ecole Française, nous avons le devoir de faire connaître celui que nous croyons le meilleur et de donner les raisons de ce choix.

Ajoutons, pour prévenir tout malentendu, qu'il ne s'agit nullement, dans notre pensée, de substituer l'alphabet latin à l'*aksar khmèr* pour la publication de textes cambodgiens, mais simplement d'établir une orthographe rationnelle pour les noms propres, les mots techniques, les citations, les exemples qu'on a l'occasion d'employer dans toute étude relative au Cambodge. Une telle orthographe est le meilleur moyen de prévenir les incertitudes et les méprises; elle a en outre l'avantage de faciliter aux débutants l'acquisition des premiers éléments de la langue.

La langue cambodgienne s'écrit au moyen d'un alphabet indien. Il semble donc tout d'abord assez naturel d'appliquer au cambodgien la transcription *littérale* en usage pour le sanscrit. Cette solution est d'une simplicité très séduisante, et il faut reconnaître qu'elle lève toutes les difficultés, sauf une: la langue parlée et la langue écrite se trouvent ainsi en complète discordance.

Cette discordance résulte principalement de deux faits :

1° Toutes les explosives *sonores* du sanscrit (à l'exception d'une seule, ड ḍa) sont des *sourdes* en khmèr; tandis que, à l'inverse, les deux sourdes, ट ṭa et प pa, sont des sonores ;

2° Les voyelles sanscrites ont pris une prononciation différente, selon qu'elles affectent une consonne sourde ou sonore en sanscrit : ainsi les signes

| | ខ | ឃ | ខិ | ឃិ | ខុ | ឃុ |
|---|---|---|---|---|---|---|
| sont en skr. | kha | gha | khĭ | ghĭ | khŭ | ghŭ |
| et en khmèr | kha | kho | khĕ | khĭ | khŏ | khŭ |



Persée creative commons BY:

C'est-à-dire qu'il s'est produit ce singulier chassé-croisé qu'une même articulation consonantique (kh) s'exprime par deux signes différents (ខ, ឃ) et qu'un même signe vocalique (p. ex. ិ) sert à exprimer deux voyelles différentes *(ĕ, ĭ)*, la modification graphique de la consonne servant ainsi à indiquer la modification phonique de la voyelle.

Si donc on appliquait la transcription littérale,

on écrirait * *bhagavatī* et on prononcerait *phokovodei* (1),
» * *purohita* » *bŏrohĕt*,
» * *nagara* » *nokor*,
» * *gajā* » *kochéa*,
» * *rājā* » *réachéa*,
» * *brahma* » *prohm*,
» * *puṇya* » *bŏn*,
» * *dharma* » *thor*,
» * *brai* » *prei*,
» * *babak* » *popok*,
» * *jīṭūn* » *chîdôn*,
» * *bhnam* » *phnom*,
» * *jhö* » *chhö*.

Ceux qui considèrent le langage comme un moyen de communication entre les hommes auront quelque peine à comprendre les mérites d'un système qui semble avoir pour but de créer à l'usage des Européens un idiome artificiel inintelligible pour les indigènes. Sans doute, rien n'empêche de donner aux signes de l'alphabet latin une valeur nouvelle, de décider, par exemple, que *ba*, *da*, *kī* se prononceront *po*, *to*, *kĕi*. De telles conventions sont légitimes, à la double condition d'être nécessaires et d'être assez rares pour ne pas imposer au lecteur de constants efforts d'attention et de mémoire. Ces deux conditions font défaut au système proposé.

Quel en est donc l'avantage ?

Ce n'est assurément pas de donner plus de clarté aux mots *khmèrs*. Car de deux choses l'une : ou bien le lecteur d'un texte khmèr ignore la langue parlée, et alors il n'a aucun motif de préférer une graphie à l'autre ; ou bien il la connaît, et il aura besoin d'une application soutenue pour reconnaître sous leur déguisement « savant » les mots qui lui sont le plus familiers. Le premier lecteur ne trouvera aucune clarté nouvelle à lire *bhnam* au lieu de *phnom* ou *brai* au lieu de *prei* ; mais le second, qui connaît les mots *phnom* et *prei*, ne manquera pas d'éprouver quelque gêne à les voir apparaître sous la forme *bhnam* et *brai*.

---

(1) Dans tous ces préliminaires nous reproduisons approximativement la prononciation, sans tenir compte du système qui sera proposé plus loin. Dès maintenant et dans tout le cours de ce travail, l'astérisque désigne les mots transcrits littéralement, de la même manière que les mots sanscrits.

En fait, ce que les défenseurs de ce système considèrent de préférence, ce ne sont pas les mots *khmèrs*, — bien qu'ils constituent après tout le fond de la langue, — ce sont les mots *indiens*. Le cambodgien, surtout le cambodgien littéraire, est mêlé dans une forte proportion de mots sanscrits ou pâlis, dont l'orthographe est généralement exacte, mais dont la prononciation barbare a de quoi surprendre, parfois même embarrasser un sanscritiste. Or il est, dit-on, un moyen très simple de lui épargner cette surprise et cet embarras : c'est de transcrire les mots, non d'après leur prononciation, qui est vicieuse, mais d'après leur orthographe, qui est correcte.

Observons tout d'abord qu'on peut couper court à toute hésitation en ajoutant, entre parenthèses, à la forme cambodgienne la forme originale, par exemple : *thor (* dharma)*, *bŏn (* puṇya)*. En second lieu, le mode de transcription que nous proposerons plus loin permet de passer sans difficulté d'une forme à l'autre. Il n'y a donc pas lieu, pour épargner un léger effort à quelques sanscritistes, d'en imposer un considérable à tous ceux qui ont à se servir du cambodgien sans connaître le sanscrit.

La transcription littérale n'est pas pratique : mais est-elle scientifique ? On l'a prétendu ; on la désigne même par le nom de « transcription scientifique ». Il est difficile de savoir sur quoi s'appuie cette prétention. Car enfin la transformation des sons à travers l'espace et le temps est, au premier chef, un objet de science ; et on ne voit pas ce qu'il y a de particulièrement scientifique à la dissimuler. Il ne saurait être plus scientifique d'écrire en cambodgien *nagar* pour *nokor* que d'écrire en français *garten* pour *jardin* ou *riding coat* pour *redingote*.

Veut-on dire par là que l'écriture a conservé un état ancien de la langue dépassé par la prononciation ; qu'en calquant la transcription sur cette écriture, nous saisissons l'évolution du langage à un stade plus voisin des origines et par suite plus favorable à l'analyse linguistique ?

Il paraît en effet résulter de la comparaison du khmèr avec les dialectes de la même famille que la *Lautverschiebung* qui a transformé les sonores sanscrites en sourdes et quelques sourdes en sonores n'est pas un fait primitif, mais le résultat d'une évolution postérieure à la fixation du langage par l'écriture.

L'assertion que l'écriture ne représente pas seulement une convention, mais une prononciation ancienne, est donc justifiée, non toutefois sans certaines exceptions.

Ainsi l'*orthographe* de certains mots sanscrits a été altérée, apparemment sous l'influence de la prononciation : or, si cette altération graphique est postérieure à la transformation phonétique dont nous venons de parler, il va de soi que les signes nouveaux ont été employés avec une autre valeur que les anciens. Par exemple les mots skr. *pavit(ra)* et *samay(a)* sont communément écrits បូពិត et សូមៃ, et se prononcent *bôpit* et *sômei* ; écrire *pūbit* et *sūmai*, c'est

produire des mots au moins hypothétiques : car il se peut que la voyelle ូ ait été ajoutée précisément pour noter la prononciation *o* du skr. *a*, et dans ce cas, les mots *pūbit* et *sūmai* n'auraient jamais été en usage.

Les mots ភ្លើង *phlöṅ* (**bhlöṅ*) « feu », et ភ្នំ *phnoṃ* (* *bhnaṃ*) « montagne », sont écrits dans les inscriptions វ្លេង *vleṅ* (= *bleṅ*), វ្នំ *vnaṃ* (= *bnaṃ*). A cette époque, la consonne initiale n'était pas aspirée. Si elle a reçu l'aspiration après être devenue sourde, ou si les deux faits ont été simultanés, la translittération **bhlöṅ*, **bhnaṃ* ne répond à aucune réalité ni moderne, ni ancienne.

Ainsi, en appliquant la transcription dite scientifique, on risque d'introduire dans la science des formes qui non seulement n'existent plus, mais qui même peuvent n'avoir jamais existé.

Elle n'est pas non plus sans inconvénient pour les études de linguistique comparative. Supposons que l'on veuille comparer la phonétique du khmèr avec celle d'un parler congénère, mais sans écriture. Comment noterons-nous cet idiome qui n'existe, lui, qu'à l'état oral? Allons-nous lui appliquer les conventions adoptées pour le khmèr ou reproduire simplement en lettres latines les sons de la voix? Dans le premier cas, il nous faudra noter des sourdes par des sonores, des consonnes identiques par des signes différents, des voyelles différentes par le même signe, sans que ce système bizarre trouve sa justification dans une écriture qui n'existe pas. Dans le second cas, nous aurons deux systèmes de notation, l'un littéral pour le khmèr, l'autre phonétique pour le dialecte; ce n'est sans doute pas le meilleur moyen de faciliter les comparaisons. On peut s'en rendre compte en examinant un travail, d'ailleurs estimable, où ce système a été employé [1]. On y trouve les rapprochements suivants: Bahnar, *kon*; Stieng, *kōn*; Khmer, *kūn*. Si on concluait de là à une différence entre le vocalisme du khmèr et celui des deux autres dialectes, on se tromperait : le mot est *kōn* en khmèr comme en stieng. Un peu plus loin, on lit : *daṅ*, ælter. Camb. « sehen »; *tiṅ*, Khmer, id. Or *daṅ* est simplement la prononciation de *tiṅ* : le mot est le même dans les deux dialectes.

Ces exemples, qu'il serait aisé de multiplier, suffisent à montrer que la translittération n'est guère mieux adaptée aux recherches linguistiques qu'aux nécessités pratiques. L'écriture est un important témoignage historique, dont il faut tenir grand compte, non toutefois au point d'en faire l'unique base de la transcription.

Un autre système s'offre à nous, c'est celui qui consiste à noter simplement les sons, abstraction faite de l'écriture : il est encore moins recommandable que le premier. On ne peut songer à fonder une notation régulière sur un élément aussi instable que la prononciation, qui varie avec les temps et les lieux, avec la

(1) P. W. Schmidt. *Die Sprachen der Sakei und Semang auf Malakka und ihr Verhältniss zu den Mon-Khmer-Sprachen.* La Haye, 1901.

condition de celui qui parle, avec l'ouïe plus ou moins fine de celui qui écoute. On n'aboutirait qu'à la confusion.

On a encore proposé d'employer concurremment les deux systèmes, selon la nature du travail : dans un récit de voyage, on userait de la notation phonétique ; dans un ouvrage d'érudition, de la notation littérale. Il y aurait une orthographe ésotérique à l'usage des savants et une orthographe exotérique pour le vulgaire. Cette combinaison ingénieuse n'aurait d'autre résultat que de compliquer encore une matière qu'il importe de simplifier : elle n'a aucune chance de succès.

| 12 | ្ឋ | th |
| 13 | ្ឌ | d |
| 14 | ្ឍ | th |
| 15 | ្ណ | n |
| 16 | ្ត | t |
| 17 | ្ថ | th |
| 18 | ្ទ | t |
| 19 | ្ធ | th |
| 20 | ្ន | n |
| 21 | ្ប | b |
| 22 | ្ផ | ph |
| 23 | ្ព | p |
| 24 | ្ភ | ph |
| 25 | ្ម | m |
| 26 | ្យ | y |
| 27 | ្រ | r |
| 28 | ្ល | l |
| 29 | ្វ | v |
| 30 | ្ស | s |
| 31 | ្ហ | h |
| 33 | ្អ | ’ |

[A] With the same base character, ្ញ is used (ញ្ញ), in all other cases only the lower element is used as subscript, e.g. ខ្ញ *khnhâ*.

# Subscript consonant characters

## III. Independent vowel characters

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | ឥ | ĕ | 3 | ឧ | ŏ,ŭ[A] | 5 | ឫ | rœ̆ | 7 | ឭ | lœ̆ | 9 | ឯ | ê | 11 | ឱ | aô[B] |
| 2 | ឦ | ei | 4 | ឪ | âu | 6 | ឬ | rœ | 8 | ឮ | lœ | 10 | ឰ | ai | 12 | ឳ | au |

[A] See note 10.

[B] Variation: ឲ.

# The Khmer Vowels and Diphthong



## Capital and other major cities

### Capital city

Lat: 11.56 | Long: 104.90 ភ្នំពេញ - Phnum Pénh

Endonym

| Language | City name | Source |
|---|---|---|
| Khmer | ភ្នំពេញ<br>*Phnum Pénh* | UNGEGN |

United Nations Languages

| Language | City name | Source |
|---|---|---|
| Arabic | بنوم بنه | UN terms |
| Chinese | 金边 | UN terms |
| English | Phnom Penh | UN terms |
| French | Phnom Penh | UN terms |
| Russian | Пномпень | UN terms |
| Spanish | Phnom Penh | UN terms |

# Bing Map


Road
Cambodia • Pursat
Siĕmréab
Angkor Wat
Bâk Préa
Phumĭ Koŭk Kduŏch
Ta Sêng
Phumĭ Pring
Phumĭ O Poŭ
Phumĭ Kâmpóng Trâbêk
Phumĭ Spéan Tnaôt
Boeng Tonte Sab
BATTAMBANG
Phumĭ Sala Vichey
Phumĭ Rônéam
Phumĭ Bat Dai
Trêng
Phumĭ Krâkaôh
Moŭng Rœssei
KAMPONG THOM
Phumĭ Svay
Phumĭ Tnaôt
Kâmpóng Thum
Svay Don Kêv
Phumĭ Chhuk
Phumĭ Trâpeăng Chông
Poŭthĭsăt
Krâkôr
Phumĭ Tnaôt Chŭm
Ta Loŭ
Sab River
Phumĭ Sâmraông
Phumĭ Thlôk
Tuŏl Kruŏs
Phumĭ Phsar
Léach
Péam Prus
PURSAT
Bâmnák
Kompong Chnang
Phumĭ Kreul
Mekong River
Phumĭ Mŏngri
Phumĭ Mól
KAMPONG CHHNANG
Phumĭ Bŏs Khnŏr
Phnom Aural 1813 m (5948 ft)
Phumĭ Phsa Rôméas
Skón
Prey Tôtœng
Khŭm Krăng Lvéa
Khŭm Bathéay
Kompong Cham
Rut
Phumĭ Ta Pôy
Phumĭ Tréa
Châmnar
Phumĭ Thmâ Kób
PHNOM PENH
Phumĭ Chŏâm
Băt Dœng
Phumĭ Kroch Saeuch
10 miles
25 km
© 2018 HERE
Feedback
© 2018 Microsoft

# 3. The Romanization system (Cont'n)

2. The system used in the second edition published Gazetteer by Geography Department in 1995-1997.

- This system is based on the system used by the Foreign Broadcast Information Service of the U.S. Government. The system refers to **the transcription method** rather than transliteration one.
- Widely use in Cambodia by all users including Census database, Google map and other GIS databases.
- For detail differences of both systems, please see **UNGEGN Technical reference manual for the standardization of geographical names, page 29-34**

**TRANSCRIPTION SYSTEM FOR KHMER**

( Prepared by Geographic Department, 1995. Last modification 1997 )

| VOWELS | | | | | CONSONANTS | | | |
|---|---|---|---|---|---|---|---|---|
| Independent | | Dependent | A-series | O-series | អឃោសៈ | A-series | ឃោសៈ | O-series |
| | | អ | a | o | ក | k | គ | k |
| | | ◌ា | a | ea | ខ | kh | ឃ | kh |
| ឥ | e | ◌ិ | e | i | ច | ch | ង | ng |
| ឦ | ei | ◌ី | ei | i | ឆ | chh | ជ | ch |
| | | ◌ឹ | oe | ue | ដ | d | ឈ | chh |
| | | ◌ឺ | eu | ueu | ឋ | th | ញ | nh |
| ឧ | o | ◌ុ | o | u | ណ | n | ឌ | d |
| ឩ | ou | ◌ូ | ou | u | ត | t | ឍ | th |
| | | ◌ួ | uo | uo | ថ | th | ទ | t |
| | | ◌ើ | aeu | eu | ប | b | ធ | th |
| | | ◌ឿ | oea | oea | ផ | ph | ន | n |
| | | ◌ៀ | ie | ie | ស | s | ព | p |
| | | ◌េ | e | e | ហ | h | ភ | ph |
| ឯ | ae | ◌ែ | ae | eae | ឡ | l | ម | m |
| ឰ | ai | ◌ៃ | ai | ey | អ | a | យ | y |
| ឱ | ao | ◌ោ | ao | ou | | | រ | r |
| ឳ | au | ◌ៅ | au | ov | | | ល | l |
| ឪ | ov | ◌ុំ | om | um | | | វ | v |

# UN system Vs Provisional system by Geography Department.

| No. | Char. | UN system | Provisional |
|---|---|---|---|
| III.3 | ឧ | ŏ, ŭ | o |
| III.- | ឩ | (*not given*) | ou |
| III.5 | ឫ | rœ̆ | rue |
| III.6 | ឬ | rœ | rueu |
| III.7 | ឭ | lœ̆ | lue |
| III.8 | ឮ | lœ | lueu |
| III.9 | ឯ | ê | ae |
| III.12 | ឪ | au | ov |
| IV.4 | ◌ឹ | œ̆ | oe—ue |
| IV.5 | ◌ឺ | œ | eu—ueu |
| IV.7 | ◌ុ | o—u | ou—u |
| IV.10 | ◌ឿ | œă | oea |
| IV.13 | ◌ែ | ê | ae—eae |
| IV.16 | ◌ៅ | au—ŏu | au—ov |
| V.2 | ◌ាំ | ă—oă,eă | (*not given*) |
| V.(2) | ◌ាក់ | (ăk—eăk) | ak—eak |
| V.3 | ◌ំ | ă—oă,eă | a—oa |
| V.(3) | ◌ំយ | (*not given*) | ai—ey |
| V.10 | ◌ោះ | aôh—ŏăh | aoh—uoh |
| V.- | ◌ះ | (*not given*) | ak—eak |
| V.- | ◌ិះ | (*not given*) | eh—is |


Google Map
Krong Siem Reap
Krong Pursat
Krong Battambang
Tonlé Sap
Chong Khneas
Kâmpóng Khleang
Kampong Kdei
Damdek
Banteay Srei
Svay Leu
Phnom Srok
Preah Netr Preah
Kralanh
Krong Serei Saophoan
Bavel
Banan
Ratanak Mondul
Koas Krala
Moung Ruessei
Samlout
Bakan
Phnom Kravanh
Krakor
Pean Bang
Chhnok Tru
Bamnak
Stoung
Krasang
Kampong Svay
Prasat Sambour District
Krong Stueng Saen
Kampong Thma
Khum Baray
Chamkar Leu District
Krong Kampong Chhnang
Tuek Phos
Kampong Tralach District
Oudongk
Thpong
Skun
Prey Chhor District
Krong Kampong Cham
Srei Santhor
Ta Sêng
Rovieng
Boeng Peae Wildlife Sanctuary
Sandan
Roneam
Svay
Vihear
Phaav
Phnum Samkoh Wildlife Sanctuary
Veal Veaeng
Mekong River
Sign in
Google
Map data ©2018 Google
Philippines
Terms
Send feedback
20 km

# 4. Topographic Database

- Since 1995 with the support of international partners, Geography Department has developed the national topographic database at a scale of 1:100,000 (for whole country), 1:5,000; 1:10,000 and 1:25,000 (on specific area) with detailed mapping features showing hydrography, contours and spot elevations, vegetation, road network, building and administrative boundaries.
- The attribute information include feature properties such as geographical names (geographical-political units, streets, mountains, rivers, lakes, etc.), names of schools, hospitals and other prominent buildings, road width, type and surface, and other information.
- The mapping features are derived from aerial photographs and high resolution satellite imageries. The attribute information is field-validated in coordination with local authorities.

# Summary

- The progress in administering of the geographical names by the National Commission on Geographical Names is slow, while some other government agencies have their own programs on geographical names.
- The Geographic Code system(GCS), that has been developed since 1994, but is still not been standardized, yet.  However, GCS is updated constantly to account for changes in the geographical-political subdivisions.
- The Department of  Geography, as the national mapping agency of the country over the past few years has collected, organized and made geospatial information more accessible to all types and levels of users.
- Currently, GD is working on a nationwide inventory of geographical features, build-up of a national topographic database and working toward updating the transcription Romanization system in UN.



# Thank you for your attention!

# ទិដ្ឋភាពទូទៅនៃភាសាខ្មែរក្នុងវចនានុក្រមខ្មែរ
# បោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨
# ( ករណី ការកត់សូរភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរ )

General Aspect of Khmer Language in Khmer Dictionary published by The Buddhist Institute 5th edition in 1967-1968

( Case Study: French and English transcribed in Khmer characters )

រៀបរៀងដោយ លោក ឃឹម វិច្ចិកា

## I- សេចក្តីផ្តើម

ភាសាជាមធ្យោបាយដែលមនុស្សប្រើប្រាស់សម្រាប់ប្រាស័យទាក់ទងគ្នានៅក្នុងសង្គម។ ភាសាខ្មែរត្រូវបានប្រជាជនខ្មែរប្រើប្រាស់និងមានប្រវត្តិយូរលង់ណាស់មកហើយ ហើយបានវិវិត្តតាមធម្មភាពរបស់ខ្លួន តែការធ្វើកូដនីយកម្មមានដូចជាសៀវភៅវេយ្យាករណ៍ វចនានុក្រមជាដើម ទើបតែចាប់ផ្តើមក្នុងរយៈពេលប៉ុន្មានទស្សវត្សរ៍ចុងក្រោយនេះទេ។ វចនានុក្រមជាការធ្វើស្តង់ដានីយកម្មទៅលើសំណេរ និងជាក្បួនអក្ខរាវិរុទ្ធមួយដែលត្រូវពឹងផ្អែកលើគោលការណ៍ណាមួយជាក់លាក់។

តាមរយៈទំនាក់ទំនងជាមួយបរទេស ភាសាខ្មែរក៏បានទទួលឥទ្ធិពលពីភាសាដែលខ្លួនមានទំនាក់ទំនងដែរ។ នៅក្នុងប្រវត្តិសាស្ត្រដ៏យូរលង់ ខ្មែរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយឥណ្ឌា ហេតុនេះ ខ្មែរបានខ្ចីពាក្យពីភាសាបាលី-សំស្ក្រឹតមកប្រើរហូតដល់ពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតខ្លះ ខ្មែរមើលលែងដឹងថាជាពាក្យកម្ចីទាល់តែអ្នកសិក្សាស្រាវជ្រាវទើបអាចដឹងពីប្រភពឫសគល់ពាក្យ។ ដោយហេតុថាប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំងជិតមួយសតវត្សរ៍ ភាសាខ្មែរបានទទួលឥទ្ធិពលពីភាសាបារាំងដែរ ហើយភាសាបារាំងត្រូវបានប្រើជាភាសាសំខាន់មួយ។ ទោះជាយ៉ាងណាក៏ដោយ ក៏ឥទ្ធិពលនេះបានថមថយចាប់ពីពាក់កណ្តាលទី២ នៃសតវត្សរ៍ទី២០ ហើយតាមរយៈសកលភាវូបនីយកម្ម ភាសាអង់គ្លេសបានក្លាយជាភាសាសំខាន់មួយដែលមានឥទ្ធិពលមកលើភាសាខ្មែរ។

នៅឆ្នាំ១៩១១ មានព្រះរាជក្រឹត្យបង្គាប់ឱ្យដាក់បង្រៀនភាសាខ្មែរនៅទូទាំងប្រទេស ប៉ុន្តែរហូតដល់ឆ្នាំ១៩២១ ទើបមានការចាប់ផ្តើមទំនើបកម្មសាលាវត្តនៅខេត្តកំពត ហើយបានរីកសាយទូទាំងប្រទេសដោយប្រើភាសាខ្មែរជាយាន។ រហូតដល់ឆ្នាំ១៩៥៣ ទើបសាលាវត្តទូទាំងប្រទេសបានក្លាយជាសាលាសាធារណៈ។ សម្រាប់ការអប់រំខាងសាសនា ភាសាបាលីគឺជាភាសាសំខាន់។ ទន្ទឹមនឹងនោះ បារាំងបានបង្កើតប្រព័ន្ធអប់រំទំនើបនៅតាមសាលាសាធារណៈ ដោយយកភាសាបារាំងជាភាសាយាន។ ដូចនេះ អាណានិគមបារាំងអនុញ្ញាតឱ្យមានការសិក្សាភាសាបីគឺ ភាសាខ្មែរសម្រាប់សាលាវត្ត ភាសាបាលីសម្រាប់សាលាបាលី និងភាសាបារាំងសម្រាប់សាលាសាធារណៈ។

នៅចុងឆ្នាំ១៩១៥ មានរាជប្រកាសបង្កើតគណៈកម្មការបង្កើតវចនានុក្រមខ្មែរដឹកនាំដោយអ្នកឧកញ៉ាចក្រីកុញ្ជរាធិបតី ពេជ្រ ប៉ុណ្ណ សេនាបតីក្រសួងសិក្សាធិការនិងយុទ្ធនាធិការ។ សំណៅវចនានុក្រមបានរៀបចំរួចរាល់

សម្រាប់ការបោះពុម្ពនៅឆ្នាំ១៩២៤ តែជាអកុសលការបោះពុម្ពវចនានុក្រមនោះមិនបានសម្រេចទេ ដោយសារមានការខ្វែងគំនិតគ្នារវាងសមាជិកនៃគណៈកម្មការអំពីសំណេរមួយចំនួន។ វចនានុក្រមខ្មែរភាគទី១ ដែលបានបោះពុម្ពនៅឆ្នាំ១៩៣៨ និងភាគទី២ នៅឆ្នាំ១៩៤៣ ជាលើកដំបូងត្រូវបានទទួលស្គាល់ថាជាបទដ្ឋានអក្ខរាវិរុទ្ធផ្លូវការ។

ការរីកចម្រើនវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាមានដំណើរទៅមុខឥតឈប់ឈរ និងដើម្បីបំពេញតម្រូវការក្នុងវិស័យអប់រំទំនើបនិងការងាររដ្ឋបាលទូទៅ គណៈកម្មការវប្បធម៌មួយដែលមានសមាសភាពភាគច្រើនជាអ្នកចេះដឹងភាសាបារាំងត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣៤ ក្នុងគោលបំណងស្រាវជ្រាវរកពាក្យបារាំងដែលប្រើប្រាស់ក្នុងវិស័យរដ្ឋបាលសាធារណៈ ច្បាប់ និងតុលាការ ព្រមទាំងក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ហើយបង្កើតពាក្យខ្មែរសងនឹងពាក្យទាំងនោះសម្រាប់បំពេញកង្វះខាតពាក្យ។

វចនានុក្រមខ្មែរដែលបានបោះពុម្ពគ្រាទី១ បានបន្តកែលម្អនិងកែសម្រួលជាច្រើនគ្រា រហូតដល់គ្រាទី៥ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ ក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីសំណាក់សម្តេចព្រះសង្ឃរាជ ជួន ណាត។ ដោយសារភាគច្រើននៃគណៈកម្មការបង្កើតវចនានុក្រមជាអ្នកស្ទាត់ជំនាញខាងភាសាបាលី-សំស្ក្រឹត គោលការណ៍អក្ខរាវិរុទ្ធបែបជាតិសព្ទត្រូវបានគេជ្រើសរើសយកមកអនុវត្តលើពាក្យកម្ចីមកពីភាសាបាលី-សំស្ក្រឹត និងពាក្យកម្ចីផ្សេងទៀត។

## II- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សានៅក្នុងបទបង្ហាញនេះផ្តោតលើទិដ្ឋភាពទូទៅនៃភាសាខ្មែរនៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨។ យើងនឹងពិនិត្យមើលថា ក្រៅពីជម្រើសពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតដែលជាភាសាដែលមានឥទ្ធិពលខ្លាំងមកលើភាសាខ្មែរ រវាងជម្រើសពាក្យកម្ចីពីភាសាបារាំងនិងភាសាអង់គ្លេស តើជម្រើសមួយណាដែលមានឧត្តមានុភាព? មូលហេតុអ្វីបានជាមានទិដ្ឋភាពបែបនេះ?

បន្ទាប់មកយើងនឹងសាកល្បងសិក្សាពីទំនោរក្នុងការកត់សូរភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរនៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៧-១៩៦៨។ តើទំនោរក្នុងការកត់សូរភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរមានលក្ខណៈបែបណា? តើជម្រើសក្នុងការកត់សូរតាមបែបជាតិសព្ទ (etymology) ដូចលំនាំពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹត ឬជម្រើសក្នុងការកត់សូរតាមបែបសូរសព្ទ (phonemic) ដែលមានឧត្តមានុភាព?

## III- វិធីសាស្ត្រស្រាវជ្រាវ

ជាដំបូង យើងស្រង់មេពាក្យនិងពាក្យទាំងអស់ដែលទាក់ទងនឹងការកត់សូរភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរនៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨។ បន្ទាប់មកយើងធ្វើចំណាត់ថ្នាក់ទិន្នន័យ។

## IV- ទិន្នន័យ

ទិន្នន័យដែលប្រមូលបានមានចំនួន១៧៨ពាក្យ ក្នុងនោះពាក្យកម្ចីពីភាសាបារាំងមានចំនួន១៧២ពាក្យ ពាក្យកម្ចីពីភាសាអង់គ្លេសមាន៥ពាក្យ និងពាក្យកម្ចីមិនច្បាស់ពីប្រភពចំនួន១ពាក្យ។

## V- ការវិភាគនិងសម្មតិកម្ម

តាមរយៈទិន្នន័យដែលបានបង្ហាញខាងលើ យើងនឹងសាកល្បងសិក្សាវិភាគទៅលើទិដ្ឋភាពទូទៅនិងទំនោរនៃការកត់សូរភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរ។

### ១- ជម្រើសរវាងពាក្យកម្ចីពីភាសាបារាំងនិងភាសាអង់គ្លេស

ទិន្នន័យបានបង្ហាញថា ការខ្ចីពាក្យពីភាសាបារាំងមានចំនួនច្រើនជាងភាសាអង់គ្លេស។ លទ្ធផលបានបង្ហាញដូចខាងក្រោម៖

| **ប្រភព** | **ចំនួនសរុប**(**ពាក្យ**) | **ភាគរយ**(%) |
|---|---|---|
| ភាសាបារាំង | ១៧២ | ៩៦,៦% |
| ភាសាអង់គ្លេស | ៥ | ៣,៤% |




*មូលហេតុអ្វីបានជានៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ មានពាក្យកម្ចីពីភាសាបារាំងច្រើនជាងភាសាអង់គ្លេស?*

ករណីនេះទាក់ទងនឹងឥទ្ធិពលនៃភាសាបារាំងមកលើភាសាខ្មែរ ព្រោះប្រទេសខ្មែរបានស្ថិតនៅក្រោមអាណាព្យាបាលនិងអាណានិគមបារាំងក្នុងរយៈពេលជិតមួយសតវត្សរ៍(១៨៨៣-១៩៥៣)។ នៅក្នុងអំឡុងពេលនោះ ភាសាបារាំងជាភាសាសំខាន់មួយនៅក្នុងរដ្ឋបាល អប់រំ និងទំនាក់ទំនង។ បន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសបារាំងនៅឆ្នាំ១៩៥៣ ភាសាបារាំងនៅតែបន្តមានឥទ្ធិពលមកលើភាសាខ្មែរ ជាពិសេសក្នុងចំណោមអ្នកមានចំណេះដឹងដែលភាគច្រើនជាអ្នកដែលបានបន្តការសិក្សានៅប្រទេសបារាំងរហូតដល់បញ្ចប់ការសិក្សាថ្នាក់បណ្ឌិត។ រីឯភាសាអង់គ្លេសវិញ ថ្វីត្បិតតែជាភាសាដែលមានសក្តានុពលខ្លាំងក៏ដោយ ក៏ភាសានេះនៅមិនទាន់មានឥទ្ធិពលខ្លាំង

មកលើភាសាខ្មែរទេ ព្រោះបារាំងជាអាណាព្យាបាល អាស្រ័យហេតុនេះ ភាសាបារាំងជាភាសាសំខាន់នៅក្នុងការប្រើប្រាស់និងទំនាក់ទំនង។

ពាក្យថ្មីៗដែលទាក់ទងនឹងរបស់ប្រើប្រាស់និងបច្ចេកវិទ្យាថ្មីៗដែលបារាំងបានផ្តល់មកដល់ខ្មែរ ខ្មែរទទួលយកប្រើដោយឥតមានទំនាស់ រហូតដល់ពេលខ្លះជម្រើសរវាងពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតដែលជាភាសាធ្លាប់មានឥទ្ធិពលយូរយារណាស់មកហើយនៅក្នុងភាសាខ្មែរនិងពាក្យកម្ចីពីភាសាបារាំង អ្នកប្រើប្រាស់ភាសាខ្មែរជ្រើសប្រើពាក្យកម្ចីពីភាសាបារាំងវិញ។ ជាក់ស្តែង ពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតមួយចំនួនដូចជា«វិទ្យុ»ត្រូវបានប្រជាជនខ្មែរសាមញ្ញនិយាយថា«រ៉ាដ្យូ (បារ. radio)» ពាក្យ«ស្ថានីយរថភ្លើង»ត្រូវបានប្រជាជនខ្មែរសាមញ្ញហៅថា«ហ្គារ៉ា (បារ. gare)» ពាក្យ «វិស្សមកាល» ត្រូវបានប្រជាជន ខ្មែរសាមញ្ញនិយាយថា «វ៉ាកង (បារ. vacance)» ជាដើម។

ដូច្នេះនៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ មានពាក្យកម្ចីពីភាសាបារាំងច្រើនជាងភាសាអង់គ្លេស។

### ២- ពហុសំណេរនៃពាក្យកម្ចីដែលមានប្រភពពីពាក្យបរទេសតែមួយ

នៅក្នុងវចនានុក្រម ពាក្យដែលខ្ចីពីភាសាបរទេសតែមួយមានសំណេរមួយបែប សំណេរពីរបែប និងសំណេរបីបែប។

លទ្ធផលបានបង្ហាញដូចខាងក្រោម៖

| **សំណេរ** | **ចំនួនសរុប (ពាក្យ)** | **ភាគរយ(%)** |
|---|---|---|
| មួយបែប | ១១៥ | ៧៩,៣% |
| ពីរបែប | ២៧ | ១៨,៦% |
| បីបែប | ៣ | ២,១% |




តាមរយៈការពិនិត្យមើលទិន្នន័យ ពហុសំណេរដែលសរសេរមានមួយបែប ពីរបែប ឬបីបែបនេះទាក់ទងនឹងទំនោរនៃការសរសេរដោយផ្អែកលើជាតិសព្ទ សូរសព្ទ និងខ្មែរនីយកម្ម។

ការណ៍នេះបានបង្ហាញថា ភាគច្រើនលើសលប់នៃទិន្នន័យបានកំណត់យកគោលការណ៍សំណេរតែមួយបែបដែលជានិន្នាការវិជ្ជមានមួយក្នុងការធ្វើឱ្យមានឯកភាពខាងសំណេរ។ ប៉ុន្តែ យើងក៏សង្កេតឃើញផងដែរថា

មានភាពមិនដាច់ស្រេចក្នុងជម្រើសនៃសំណេរ ដោយសារក្នុងពាក្យកម្ចីពីបរទេសតែមួយ អាចមានសំណេរតាមបែបជាតិសព្ទផង តាមបែបសូរសព្ទផង និងខ្មែរនីយកម្មផងដែរ។

ឧទាហរណ៍

| | | |
|---|---|---|
| **សំណេរមួយបែបនៃពាក្យកម្ចីតែមួយ** | | |
| «គីមី» | បារ. Chimie | ទំព័រ១៣៤ |
| «កុងស៊ីយ៍» | បារ. Conseil | ទំព័រ៤១ |
| «កាសែត» | បារ. Gazette | ទំព័រ៣១ |
| «លួី» | បារ. Louis | ទំព័រ១១០ |
| **សំណេរពីរបែបនៃពាក្យកម្ចីតែមួយ** | | |
| «ឡូ» | បារ. Lot | ទំព័រ១៥៤៧ |
| «ឡូត៍» | បារ. Lot | ទំព័រ១៥៤៧ |
| គ្លាម | បារ. Gomme | ទំព័រ១៥០៤ |
| ហ្គោម | បារ. Gomme | ទំព័រ១៥០៤ |
| **សំណេរបីបែបនៃពាក្យកម្ចីតែមួយ** | | |
| «អាម៉េរិក» | បារ. Amérique | ទំព័រ១៧៤២ |
| «អាម៉េរិគ» | បារ. Amérique | ទំព័រ១៧៤២ |
| «អាម៉េរិគឹ» | បារ. Amérique | ទំព័រ១៧៤២ |
| | | |
| «កាត» | បារ. Carte | ទំព័រ៣១ |
| «កាត៌» | បារ. Carte | ទំព័រ៣១ |
| «កាដ្ត៍» | បារ. Carte | ទំព័រ៣១ |

យើងឃើញថាពហុភាពនៃសំណេរនេះអាចជាការសាកល្បងអនុវត្តគោលការណ៍សំណេរបែបសូរសព្ទ និងការធ្វើខ្មែរនីយកម្មទៅលើពាក្យកម្ចី ដែលពីដើមរៀងមក គោលការណ៍ជាតិសព្ទត្រូវបានអនុវត្តទៅលើពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹត។ ការសាកល្បងនេះអាចជាការស្ទង់មតិអ្នកប្រើភាសាខ្មែរទៅលើទំនោរអក្ខរាវិរុទ្ធខ្មែរ។

### ៣- សំណេរតាមបែបជាតិសព្ទ សូរសព្ទ និងខ្មែរនីយកម្ម

ការកំណត់គោលការណ៍សំណេរមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យមានឯកភាព។ ភាគច្រើននៃគណៈកម្មការបង្កើតវចនានុក្រមជាអ្នកស្ទាត់ជំនាញខាងភាសាបាលី-សំស្ក្រឹត ដូច្នេះគោលការណ៍អក្ខរាវិរុទ្ធបែបជាតិសព្ទត្រូវបានគេជ្រើសរើសយកមកអនុវត្តលើពាក្យកម្ចីមកពីភាសាបាលី-សំស្ក្រឹតនិងពាក្យកម្ចីផ្សេងទៀត។

យើងនឹងសាកល្បងពិនិត្យមើលថា ***តើគោលការណ៍អក្ខរាវិរុទ្ធដោយយកសំណេរតាមបែបជាតិសព្ទអនុវត្តលើពាក្យកម្ចីពីភាសាបារាំងនិងភាសាអង់គ្លេសដែរឬទេ?***

តាមរយៈការវិភាគទិន្នន័យ លទ្ធផលបានបង្ហាញដូចខាងក្រោម៖

| **សំណេរ** | **ចំនួនសរុប (ពាក្យ)** | **ភាគរយ(%)** |
|---|---|---|
| ជាតិសព្ទ | ៧៨ | ៤៣,៨% |
| សូរសព្ទ | ៩៤ | ៥២,៨% |
| ខ្មែរនីយកម្ម | ៦ | ៣,៤% |




លទ្ធផលបានបង្ហាញថា ការអនុវត្តគោលការណ៍អក្ខរាវិរុទ្ធតាមបែបជាតិសព្ទដែលអនុវត្តទៅលើពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតមិនបានអនុវត្តទាំងស្រុងចំពោះពាក្យកម្ចីពីភាសាបារាំងនិងភាសាអង់គ្លេសទេ។ ជាងនេះទៅទៀត យើងឃើញថា ទំនោរនៃការសរសេរសំណេរតាមបែបសូរសព្ទមានចំនួនច្រើនជាងសំណេរតាមបែបជាតិសព្ទ។ ម្យ៉ាងទៀត យើងក៏សង្កេតឃើញមាននិន្នាការក្នុងការធ្វើខ្មែរនីយកម្មទៅលើពាក្យកម្ចីផងដែរ ប៉ុន្តែនិន្នាការនេះនៅមិនទាន់មានភាពទូលំទូលាយនៅឡើយ។

ឧទាហរណ៍

| សំណេរតាមបែបជាតិសព្ទ | | |
|---|---|---|
| «ប៊ីស៊ិក្លែត្ដ៍» | បារ. Bicyclette | ទំព័រ៩៨៥ |
| «ម៉ុងត្រ៍» | បារ. Montre | ទំព័រ៩១៥ |
| «ស៊ូប៊ុ» | បារ. Soupe | ទំព័រ១៣៧៦ |
| **សំណេរតាមបែបសូរសព្ទ** | | |
| «កុងស៊ុល» | បារ. Consult | ទំព័រ៤១ |
| «អាហ្ស៊ី» | បារ. Asie | ទំព័រ១៧៦០ |
| «សាប៊ុង» | បារ. Savon | ទំព័រ១២៦៧ |
| **សំណេរតាមបែបខ្មែរនីយកម្ម** | | |
| «បារាំងសែស» | បារ. Française | ទំព័រ២៤ |
| «ម៉ោង» | បារ. Montre | ទំព័រ៩១៥ |
| «ក្រាម» | បារ. Gramme | ទំព័រ៨៤ |

*មូលហេតុអ្វីបានជាសំណេរតាមបែបសូរសព្ទមានចំនួនច្រើនជាងសំណេរតាមបែបជាតិសព្ទ?*

ការណ៍នេះអាចទាក់ទងនឹងបញ្ហាក្នុងការសរសេរ។ សំណេរតាមបែបជាតិសព្ទធ្វើឱ្យសំណេរពាក្យពិបាកក្នុងការអានឬការមើល ដោយសារសំណេរបែបនេះត្រូវសរសេរអក្សរដែលមិនអានឱ្យឮសូរនិងត្រូវប្រើវណ្ណយុត្តច្រើន។

ឧទាហរណ៍

| សំណេរបែបជាតិសព្ទ | | |
|---|---|---|
| «កាត៌», «កាក៏» | បារ. Carte | ទំព័រ៣១ |
| «ហ្វ្រង្គ» | បារ. Franc | ទំព័រ១៥៤០ |
| «ហ្វ្រង្សេស៍» | បារ. Français | ទំព័រ៥៦៩ |
| «តែមប្រឹប៉ុស្ដ៍» | បារ. Timbre-poste | ទំព័រ៣៥៤ |
| «ទ្រីស៊ិក្ល៏» | បារ. Tricycle | ទំព័រ៩៨៥ |

ចំណែកឯសំណេរតាមបែបសូរសព្ទ មានភាពងាយស្រួលជាង ដោយសារសំណេរបែបនេះសរសេរតែអក្សរណាដែលអានឱ្យឮសូរ។

ឧទាហរណ៍

| សំណេរបែបសូរសព្ទ | | |
|---|---|---|
| «កាត» | បារ. Carte | ទំព័រ៣១ |
| «អូតូ» | បារ. Auto | ទំព័រ៩៨៦ |
| «បេតុង» | បារ. Béton | ទំព័រ១៣៥៩ |
| «ក្រែប» | បារ. Crêpe | ទំព័រ៨៨ |
| «តុងទីន» | បារ. tontine | ទំព័រ៣៤៨ |

ដូច្នេះ យើងសង្កេតឃើញថា ការសម្រួលសំណេរឱ្យងាយស្រួលក្នុងការសរសេរ ការមើល និងការអាន ជាគោលការណ៍មួយដែលបានចាប់ផ្ដើមអនុវត្តនៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨។

***តើគោលការណ៍នេះមានផលវិជ្ជមាននិងអវិជ្ជមានអ្វីខ្លះ?***

សំណេរតាមបែបសូរសព្ទជាសំណេរដែលធ្វើឱ្យអ្នកប្រើភាសាខ្មែរងាយស្រួលក្នុងការសរសេរ ការមើល និងការអាន។ សំណេរបែបនេះស្របនឹងការធ្វើខ្មែរនីយកម្មទៅលើពាក្យកម្ចីពីភាសាបរទេស។ ប៉ុន្តែ ការសម្រួលសំណេរអាចធ្វើឱ្យប៉ះពាល់ដល់ប្រវត្តិឫសគល់នៃពាក្យ ដែលធ្វើឱ្យយើងនឹងពិបាកស្រាវជ្រាវរកប្រភពឫសគល់នៃពាក្យនៅថ្ងៃអនាគត។

## VI- **សេចក្ដីសន្និដ្ឋាន**

តាមរយៈការសាកល្បងសិក្សាទិន្នន័យដែលប្រមូលបាននៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ យើងអាចសន្និដ្ឋានបានថា ការខ្ចីពាក្យពីភាសាបារាំងមានចំនួនច្រើនជាងភាសាអង់គ្លេស ព្រោះនៅក្នុងបរិបទនោះ ភាសាខ្មែរទទួលឥទ្ធិពលខ្លាំងពីភាសាបារាំង។ ម្យ៉ាងទៀត ពហុភាពនៃសំណេរទាក់ទងនឹងទំនោរនៃសំណេរបែបជាតិសព្ទ សំណេរបែបសូរសព្ទ និងសំណេរបែបខ្មែរនីយកម្ម។ ក្នុងនោះផងដែរ ការអនុវត្តគោលការណ៍សំណេរបែបជាតិសព្ទមិនបានអនុវត្តទាំងស្រុងទៅលើពាក្យកម្ចីពីភាសាបរទេសទេ។ ចំពោះការកត់សូរពីភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរ ទំនោរនៃការអនុវត្តគោលការណ៍សំណេរបែបសូរសព្ទមានចំនួនច្រើនជាងទំនោរនៃការអនុវត្តគោលការណ៍សំណេរបែបជាតិសព្ទ។ រីឯការអនុវត្តគោលការណ៍សំណេរបែបខ្មែរនីយកម្មមានចំនួនតិចតួចនៅឡើយ។

ការសិក្សានេះមានរយៈពេលខ្លី ស្ទើរមិនទាន់បានសិក្សាវិភាគលម្អិតអំពីទំនោរនៃការកត់សូរព្យញ្ជនៈនិងស្រៈនៃភាសាបារាំងនិងភាសាអង់គ្លេសជាអក្សរខ្មែរនៅឡើយទេ។ ម្យ៉ាងទៀត យើងឃើញមានការបង្កើតតួអក្សរថ្មីមួយចំនួនសម្រាប់កត់ត្រាសូរនៃភាសាបារាំងនិងភាសាអង់គ្លេសដូចជា «ស្ហ» ក្នុងពាក្យ «ស្ហែហ្វ» បារ. Chef ទំព័រ១៥០៤ «គ្ហ»និង«ហ្គ» ក្នុងពាក្យ «គ្ហារ»និង«ហ្គារ» បារ. Gare ទំព័រ១៥០៤ ជាដើម។

តើការបង្កើតតួអក្សរថ្មីសម្រាប់កត់ត្រាសូរនៃភាសាបរទេសមានភាពចាំបាច់ដែរឬទេ? តើមានផលវិជ្ជមាន និងអវិជ្ជមានបែបណាខ្លះនៅក្នុងភាសាខ្មែរ?

តើគោលការណ៍សំណេរបែបជាតិសព្ទនិងគោលការណ៍សំណេរបែបសូរសព្ទមានផលវិជ្ជមាននិងអវិជ្ជមាន បែបណាខ្លះក្នុងការកត់សូរភាសាបរទេសជាអក្សរខ្មែរ និងការកត់សូរភាសាខ្មែរជាអក្សរឡាតាំង?

ស្មេរសង្ឃឹមថានឹងមានការសិក្សាវិភាគលម្អិតជាបន្តទៀត។

## VII- **អនុសាសន៍**

នៅក្នុងវចនានុក្រម តើគួរអនុវត្តគោលការណ៍សំណេរតាមបែបជាតិសព្ទ សូរសព្ទ ឬខ្មែរនីយកម្ម?

ការជ្រើសរើសយកគោលការណ៍ជាតិសព្ទធ្វើឱ្យសំណេរពាក្យពិបាកនិងស្មុគស្មាញ តែអាចឱ្យអ្នកប្រើភាសាដឹងពីប្រភពឫសគល់នៃពាក្យ។ រីឯការជ្រើសរើសយកគោលការណ៍សំណេរតាមបែបសូរសព្ទ មានភាពងាយស្រួលដែលជួយសម្រួលដល់ការសរសេរ ការមើល និងការអាន ហើយវាក៏ស្របនឹងគោលការណ៍ខ្មែរនីយកម្មផងដែរ។

នៅក្នុងវចនានុក្រម យើងគួរជ្រើសរើសយកគោលការណ៍តែមួយដើម្បីឱ្យមានឯកភាពក្នុងសំណេរ។ ប្រសិនបើយើងអនុវត្តគោលការណ៍សំណេរទាំងបីខាងលើក្នុងពាក្យកម្ចីតែមួយ យើងនឹងបង្កើតឱ្យមានពហុភាពនៃសំណេរនិងធ្វើឱ្យប៉ះពាល់ដល់ការស្វែងរកឯកភាពអក្ខរាវិរុទ្ធខ្មែរ។

ចំពោះការអនុវត្តការកត់សូរភាសាខ្មែរជាអក្សរឡាតាំង យើងឃើញថាស្ថាប័នជាតិនិងអន្តរជាតិបានជ្រើសរើសយកការកត់ត្រាដោយប្រើអក្ខរវិធីសំណង(Transliteration)បែបជាតិសព្ទ។

ដូច្នេះ តើប្រព័ន្ធសំណេរបែបសូរសព្ទត្រូវយកមកអនុវត្តបន្តទៀតដែរឬទេ?

## VIII- **គន្ថនិទ្ទេស**


- ក្រសួងអប់រំជាតិ៖ ***សទ្ទានុក្រមខេមរយានកម្ម បារាំង-ខ្មែរ*** វិទ្យាស្ថានជាតិខេមរយានកម្ម ភ្នំពេញ ១៩៧៣
- ជួន ណាត៖ ***វចនានុក្រមខ្មែរ (ភាគ១-២)*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ភ្នំពេញ ១៩៦៧-១៩៦៨
- តិប យក់ និង ថាវ គន្ធ៖ ***វចនានុក្រម បារាំង-ខ្មែរ (ភាគ១-២)*** បណ្ណាគារ ប៊ុត នាង ភ្នំពេញ ១៩៦២
- https://en.m.wikipedia.org/wiki/Romanization_of_Khmer
- https://unstats.un.org/unsd/geoinfo/UNGEGN/docs/11thuncsgndocs/E_Conf.105_54_CRP.54_6_11 UNCS GN_WGRS_report.pdf
- https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/693723/ROMANIZATION_OF_KHMER.pdf
- https://www.eki.ee/wgrs/wgr06_8.pdf
- http://www.eki.ee/wgrs/rom1_km.pdf
- https://www.loc.gov/catdir/cpso/romanization/khmer.pdf
- https://unstats.un.org/unsd/geoinfo/UNGEGN/docs/8th-uncsgn-docs/inf/8th_UNCSGN_econf.94_INF.30_corr1.pdf

## ៤- គោលការណ៍បណ្ដោះអាសន្ននៃការប្រើប្រាស់អក្សរឡាតាំងសម្រាប់កត់សូរភាសាខ្មែរ

ស្ថាប័នជាតិនិងអន្តរជាតិជាច្រើនបានប្រើប្រាស់អក្សរឡាតាំងសម្រាប់កត់សូរភាសាខ្មែរ។ ស្ថាប័នជាតិមានដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងផែនការ ក្រសួងមហាផ្ទៃ ជាដើម។ ស្ថាប័នអន្តរជាតិមានដូចជាស្ថាប័ន US Board on Geographic Names (BGN) / Permanent Committee on Geographical Names for British Official Use (PCGN) ស្ថាប័ន United Nations Romanization Systems for Geographical Names (UNRSGN) ស្ថាប័ន American Library Association - Library of Congress (ALA-LC) ជាដើម។

ការប្រើប្រាស់អក្សរឡាតាំងសម្រាប់កត់សូរភាសាខ្មែរមិនទាន់មានឯកភាពគ្នានៅឡើយទាំងស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិ។ នៅក្នុងកិច្ចប្រជុំផ្ទៃក្នុងរវាងតំណាងគណៈកម្មការភាសាវិទ្យា គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន និងគណៈកម្មការបង្កើតពាក្យនិងកម្រងពាក្យនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ អង្គប្រជុំបានពិនិត្យពិភាក្សាបញ្ហាគោលការណ៍សំណេរពាក្យ ការកំណត់សញ្ញាព្យញ្ជនៈនិងស្រៈខ្មែរជាអក្សរឡាតាំង និងករណីលើកលែង។

### I- បញ្ហាគោលការណ៍សំណេរពាក្យ

ការកំណត់គោលការណ៍សំណេរអក្សរខ្មែរជាអក្សរឡាតាំងទាក់ទងនឹងគោលការណ៍សំណេរពាក្យកម្ចី។ កន្លងមកក្នុងវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតអនុវត្តសំណេរតក្សរូប (ជាតិសព្ទ) ចំណែកពាក្យកម្ចីពីភាសាបារាំងនិងភាសាអង់គ្លេស មានសំណេរបីបែប សំណេរតក្សរូប សំណេរតាមសូរ និងសំណេរខ្មែរនីយកម្ម ឧទាហរណ៍ **ប៊ីស៊ិក្លែត្តិ៍ កុងស៊ុល ក្រាម** ។ល។ ម្យ៉ាងទៀត ពាក្យដែលក្រុមប្រឹក្សាអនុម័តក៏មានសំណេរខ្លះតក្សរូប សំណេរខ្លះតាមសូរផងដែរ ឧទាហរណ៍ **បាស៊ីយ៍ ស្តង់ដា**។ល។ អង្គប្រជុំនឹងធ្វើការសម្រេចចិត្តចុងក្រោយបន្ទាប់ពីបានពិនិត្យទិន្នន័យដែលស្រង់ចេញពីវចនានុក្រមខ្មែរ និងទិន្នន័យដែលក្រុមប្រឹក្សាជាតិភាសាខ្មែរបានអនុម័តរួច ដើម្បីពិនិត្យមើលនិងជ្រើសរើសទំនោរសំណេរតក្សរូបឬទំនោរសំណេរតាមសូរ។

អង្គប្រជុំបានសម្រេចជាបណ្ដោះអាសន្នដូចខាងក្រោមៈ

១- ចំពោះគោលការណ៍សំណេរពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតត្រូវរក្សាគោលការណ៍សំណេរតក្សរូប ឧទាហរណ៍ **ទូរទស្សន៍ ពោធិ៍** ។ល។ រីឯពាក្យកម្ចីក្រៅពីភាសាបាលី-សំស្ក្រឹត សំណេរត្រូវយកសំណេរសូរ ឧទាហរណ៍ **ឡូ គីមី** ។ល។

២- គោលការណ៍ក្នុងការកត់ត្រាអក្សរខ្មែរជាអក្សរឡាតាំង

-ក្នុងការញែកមូលភេទអអិ យើងត្រូវប្រើសញ្ញាប្លែកគ្នា។ ចំពោះស្រៈ តាមគោលការណ៍អអិ យើងត្រូវមានសញ្ញាខុសគ្នាលើកលែងតែស្រៈខ្លីនិងស្រៈវែង។ យើងទទួលប្រើវណ្ណយុត្តចំនួនបីរបស់ភាសាបារាំងដែលប្រើលើស្រៈនៃអក្សរឡាតាំងសម្រាប់កត់ត្រាស្រៈក្នុងភាសាខ្មែរគឺ ទី១ «accent aigu» ប្រើសញ្ញា« ΄ » ទី២ «accent grave» ប្រើសញ្ញា« ` » និងទី៣ «accent circonflexe» ប្រើសញ្ញា« ^ » ដើម្បីញែកស្រៈឱ្យមានភាពខុសប្លែកគ្នាចៀសវាងការប្រើអក្សរឡាតាំងតែមួយកត់ត្រាស្រៈជាច្រើនក្នុងភាសាខ្មែរ។

ឧទាហរណ៍នៃការប្រើសញ្ញាវណ្ណយុត្ត

ស្រៈ«ែ» ត្រូវកត់ត្រាជាអក្សរឡាតាំង សម្រាប់ពួកអ«ê» និងសម្រាប់ពួកអ៊«è»។

ពាក្យ «ចែង» ត្រូវកត់ជាអក្សរឡាតាំង«chêng» និងពាក្យ «វែង» ត្រូវកត់ជាអក្សរឡាតាំង «vèng»។

ស្រៈ«េ»ត្រូវកត់ត្រាជាអក្សរឡាតាំង សម្រាប់ពួកអ«e» និងសម្រាប់ពួកអ៊«é»។

ពាក្យ «ចេក» ត្រូវកត់ជាអក្សរឡាតាំង«chek» និងពាក្យ «ពេល» ត្រូវកត់ជាអក្សរឡាតាំង «pél»។

ឧទាហរណ៍នៃការមិនបែងចែកស្រៈខ្លីនិងស្រៈវែង

ស្រៈ «ុ»និងស្រៈ«ូ» ត្រូវកត់ត្រាជាអក្សរឡាតាំង សម្រាប់ពួកអ«o» និងសម្រាប់ពួកអ៊«u»។

ពាក្យ «កុក» ត្រូវកត់ត្រាជាអក្សរឡាតាំង«kok» និងពាក្យ «គុក» ត្រូវកត់ត្រាជាអក្សរឡាតាំង«kuk»។

ពាក្យ «កូក» ត្រូវកត់ត្រាជាអក្សរឡាតាំង«kok» និងពាក្យ «គូក» ត្រូវកត់ត្រាជាអក្សរឡាតាំង«kuk»។

ឧទាហរណ៍នៃការប្រើសញ្ញា«o»ស្ទួនដើម្បីញែកស្រៈ«ោ» ជាពួកអនិងពួកអ៊

ស្រៈ «ោ» ត្រូវកត់ត្រាជាអក្សរឡាតាំង សម្រាប់ពួកអ«ao» និងសម្រាប់ពួកអ៊«oo»។

ពាក្យ «កោរ» ត្រូវកត់ត្រាជាអក្សរឡាតាំង«kao» និងពាក្យ «គោ» ត្រូវកត់ត្រាជាអក្សរឡាតាំង«koo»។

- ចំពោះសញ្ញាព្យញ្ជនៈខ្មែរដែលកត់ត្រាជាអក្សរឡាតាំងត្រូវកំណត់ដូចខាងក្រោម៖

សញ្ញាព្យញ្ជនៈខ្មែរពួកអនិងពួកអ៊ត្រូវកត់ត្រាជាអក្សរឡាតាំងមួយតួ

ឧទាហរណ៍ ព្យញ្ជនៈពួកអ «ក»និងព្យញ្ជនៈពួកអ៊ «គ»ត្រូវកត់ត្រាជាអក្សរឡាតាំង«k»។

ពាក្យ«កា»ត្រូវកត់ត្រាជាអក្សរឡាតាំង«ka» និងពាក្យ «គា» ត្រូវកត់ត្រាជាអក្សរឡាតាំង«kea»។

សញ្ញាព្យញ្ជនៈខ្មែរពួកអនិងពួកអ៊ត្រូវកត់ត្រាជាអក្សរឡាតាំងពីរតួ

ឧទាហរណ៍ ព្យញ្ជនៈពួកអ «ច»និងព្យញ្ជនៈពួកអ៊ «ជ»ត្រូវកត់ត្រាជាអក្សរឡាតាំង«ch»។

ពាក្យ«ចាក់»ត្រូវកត់ត្រាជាអក្សរឡាតាំង«chak» និងពាក្យ «ជាក់» ត្រូវកត់ត្រាជាអក្សរឡាតាំង«cheak»។

សញ្ញាព្យញ្ជនៈខ្មែរពួកអនិងពួកអ៊ត្រូវកត់ត្រាជាអក្សរឡាតាំងបីតួ

ឧទាហរណ៍ ព្យញ្ជនៈពួកអ «ឆ»និងព្យញ្ជនៈពួកអ៊ «ឈ»ត្រូវកត់ត្រាជាអក្សរឡាតាំង«chh»។

ពាក្យ«ឆក»ត្រូវកត់ត្រាជាអក្សរឡាតាំង«chhâk» និងពាក្យ «ឈូ» ត្រូវកត់ត្រាជាអក្សរឡាតាំង«chhu»។

សញ្ញាព្យញ្ជនៈ«អ»ស្ថិតនៅទីតាំងខាងដើមព្យាង្គត្រូវកត់ត្រាជាសញ្ញាស្រៈ ហើយប្រសិនបើសញ្ញាព្យញ្ជនៈ «អ» ស្ថិតនៅទីតាំងទី២ក្នុងព្យញ្ជនៈផ្សំ សញ្ញាព្យញ្ជនៈ«អ»នេះត្រូវកត់ត្រាជាសញ្ញ apostrophe «ʼ»

ឧទាហរណ៍ ពាក្យ «អណ្តូង»ត្រូវកត់ត្រាជាអក្សរឡាតាំង«ândong»

ពាក្យ «អាង»ត្រូវកត់ត្រាជាអក្សរឡាតាំង«ang»

ពាក្យ «អូរ»ត្រូវកត់ត្រាជាអក្សរឡាតាំង«o»

ពាក្យ «ស្អាង»ត្រូវកត់ត្រាជាអក្សរឡាតាំង«sʼang»

- ចំពោះព្យញ្ជនៈ មានសញ្ញាបន្ថែម«ហ្គ»«ហ្គ»«ហ្វ»«ហ្វ៊»«ហ្ស»«ហ្ស៊»«ស្ហ»សម្រាប់កត់សូរភាសាបរទេស។ សញ្ញា«ហ្គ»និង«ហ្គ៊» កត់ត្រាសូរ [g] សញ្ញា«ហ្វ»និង«ហ្វ៊»កត់ត្រាសូរ [f] សញ្ញា«ហ្ស»និង«ហ្ស៊»កត់ត្រាសូរ [z] និង សញ្ញា«ស្ហ»និង«ស្ហ៊»កត់ត្រាសូរ [ʃ] តាមការកំណត់របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ។ ប៉ុន្តែ ក្នុងករណីព្យញ្ជនៈផ្សំ យើង

ត្រូវយកសំឡេងដូចឬស្រដៀងភាសាខ្មែរដោយសម្រួលសំណេរយកព្យញ្ជនៈខ្មែរដែលមានស្រាប់ ដើម្បីដោះស្រាយបញ្ហាការសរសេរត្រួតគ្នាច្រើនជាន់។ អង្គប្រជុំបានសម្រេចគោលការណ៍ក្នុងការសរសេរដូចខាងក្រោម៖

ចំពោះព្យញ្ជនៈទោល ការសរសេរជាព្យញ្ជនៈខ្មែរត្រូវគោរពតាមការកំណត់របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលបានកំណត់រួចហើយ ឧទាហរណ៍ ពាក្យ «Mongolie»ត្រូវកត់ត្រាជា «ម៉ុងហ្គោលី» ពាក្យ«café» ត្រូវកត់ត្រាជា «កាហ្វេ» ។ល។

ចំពោះព្យញ្ជនៈផ្សំ ការសរសេរជាព្យញ្ជនៈខ្មែរត្រូវសម្រួលសំណេរតាមបែបខ្មែរ ឧទាហរណ៍ ពាក្យ«glucide» ត្រូវកត់ត្រាជា«គ្លុយស៊ីដ» ដោយមិនសរសេរជា«ហ្គ្លុយស៊ីដ»ទេ។ល។ (លើកលែងតែ «ហ្វ្រ» ឧទាហរណ៍ អាហ្វ្រិក ដែលក្រុមប្រឹក្សាជាតិភាសាខ្មែរអនុម័តរួចហើយ ? )

## II- **ការកំណត់ព្យញ្ជនៈនិងស្រៈជាអក្សរឡាតាំង**

១- សញ្ញាព្យញ្ជនៈខ្មែរដែលកត់ត្រាជាអក្សរឡាតាំងត្រូវកំណត់ដូចខាងក្រោម៖

| តួអក្សរព្យញ្ជនៈខ្មែរ ពួកអ | សំណើអក្សរឡាតាំង | តួអក្សរព្យញ្ជនៈខ្មែរ ពួកអ៊ | សំណើអក្សរឡាតាំង |
|---|---|---|---|
| ក | k | គ | k |
| ខ | kh | ឃ | kh |
| | | ង | ng |
| ច | ch | ជ | ch |
| ឆ | chh | ឈ | chh |
| | | ញ | nh |
| ដ | d | ឌ | d |
| ឋ | th | ឍ | th |
| ត | t | ទ | t |
| ថ | th | ធ | th |
| ណ | n | ន | n |
| ប | b | | |
| | | ព | p |
| ផ | ph | ភ | ph |
| | | ម | m |
| | | យ | y |
| | | រ | r |
| ឡ | l | ល | l |
| | | វ | v |
| ស | s | | |
| ហ | h | | |

២- សញ្ញាស្រៈខ្មែរដែលកត់ត្រាជាអក្សរឡាតាំងត្រូវកំណត់ដូចខាងក្រោម៖

| ស្រៈនិស្ស័យ | សំណើអក្សរឡាតាំង សម្រាប់កត់ត្រាពួកអ | សំណើអក្សរឡាតាំង សម្រាប់កត់ត្រាពួកអ៊ |
|---|---|---|
| \| | â | ô |
| ◌ា | a | ea |
| ◌ិ | e | i |
| ◌ី | ei | i |
| ◌ឹ | oe | ue |
| ◌ឺ | oe | ue |
| ◌ុ | o | u |
| ◌ូ | o | u |
| ◌ួ | uo | uo |
| ◌ើ | ae | eu |
| ◌ឿ | oeu | oeu |
| ◌ៀ | ie | ie |
| េ◌ | e | é |
| ែ◌ | ê | è |
| ៃ◌ | ai | ey |
| ◌ោ | ao | oo |
| ◌ៅ | au | ou |
| ◌ុំ | om | um |
| ◌ំ | âm | um |
| ◌ាំ | am | oam |
| ◌ះ | ah | eah |
| ◌ុះ | oh | uh |
| េ◌ះ | eh | ih |
| ◌ោះ | aoh | uoh |
| ◌ិះ | eh | ih |
| ◌ាំង | ang | eang |
| ◌ឹះ | oeh | ueh |

| ស្រៈពេញតួ | សំណើអក្សរឡាតាំង |
|---|---|
| ឥ | e |
| ឦ | ei |
| ឧ | o |
| ឩ | o |
| ឯ | ê |
| ឰ | ai |
| ឱ | ao |
| ឳ | ov |
| ឫ | rue |
| ឬ | rue |
| ឭ | lue |
| ឮ | lue |
| ឪ | au |

| សំយោគសញ្ញា | សំណើអក្សរឡាតាំងសម្រាប់កត់ត្រាពួកអ | សំណើអក្សរឡាតាំងសម្រាប់កត់ត្រាពួកអ |
|---|---|---|
| ័ | a | oa |
| ័ង | ang | eang |
| ័ក | ak | eak |
| ័យ | ai | ey |

ចំពោះពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹតដែលមានប្រើឬមិនប្រើយុគលពិន្ទុ( ះ) យើងត្រូវកត់ត្រាជា «ak» សម្រាប់ពួកអ និង«eak»សម្រាប់ពួកអ៊ិ។

ឧទាហរណ៍ ពាក្យ«សេដ្ឋកិច្ច» ត្រូវកត់ត្រាជាអក្សរឡាតាំង «sedthakkech»

ពាក្យ«យុត្តះ» ត្រូវកត់ត្រាជាអក្សរឡាតាំង «yuttak»

២- ការប្រៀបធៀបការកំណត់ស្រៈជាអក្សរឡាតាំងរបស់ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការកំណត់របស់អង្គការសហប្រជាជាតិ( US Board on Geographic Names ( BGN ) / Permanent Committee on Geographical Names for British Official Use ( PCGN ), United Nations Romanization Systems for Geographical Names ( UNRSGN )

| | ក្រសួងទាំង៣ | | BGN/PCGN | | សំណើថ្មី | |
|---|---|---|---|---|---|---|
| ស្រៈនិស្ស័យ | អក្សរឡាតាំង ពួកអ | អក្សរឡាតាំង ពួកអ៊ | អក្សរឡាតាំង ពួកអ | អក្សរឡាតាំង ពួកអ៊ | អក្សរឡាតាំង ពួកអ | អក្សរឡាតាំង ពួកអ៊ |
| ı | a | o | â | ô | â | ô |
| ◌ា | a | ea | a | éa | a | ea |
| ◌ិ | e | i | ĕ | ĭ | e | i |
| ◌ី | ei | i | ei | i | ei | i |
| ◌ឹ | oe | ue | œ̆ | œ̆ | oe | ue |
| ◌ឺ | eu | ueu | œ | œ | oe | ue |
| ◌ុ | o | u | ŏ | ŭ | o | u |
| ◌ូ | ou | u | o | u | o | u |
| ◌ួ | uo | uo | uŏ | uŏ | uo | uo |
| ◌ើ | aeu | eu | aeu | eu | ae | eu |
| ◌ឿ | oea | oea | œă | œă | oeu | oeu |
| ◌ៀ | ie | ie | iĕ | iĕ | ie | ie |
| ◌េ | e | e | é | é | e | é |
| ◌ែ | ae | eae | ê | ê | ê | è |
| ◌ៃ | ai | ey | ai | ey | ai | ey |
| ◌ោ | ao | ou | aô | oŭ | ao | oo |
| ◌ៅ | au | ov | au | ŏu | au | ou |
| ◌ុំ | om | um | om | ŭm | om | um |
| ◌ំ | am | um | âm | um | âm | um |
| ◌ាំ | am | oam | ăm | ŏâm | am | oam |
| ◌ះ | ah | eah | ăh | eăh | ah | eah |
| ◌ុះ | oh | uh | ŏh | ŭh | oh | uh |
| ◌េះ | eh | eh | éh | éh | eh | ih |
| ◌ោះ | aoh | uoh | aôh | ŏăh | aoh | uoh |
| ◌ិះ | eh | is | | | eh | ih |
| ◌ាំង | ang | eang | ăng | eăng | ang | eang |
| ◌ឹះ | | | | | oeh | ueh |

III- **ករណីលើកលែង**

អសាធារណនាមដូចជាឈ្មោះទីកន្លែង ទីតាំងប្រវត្តិសាស្ត្រ ព្រះនាមរបស់ព្រះមហាក្សត្រ ឈ្មោះបុគ្គលសំខាន់ៗជាដើម ដែលមហាជនស្គាល់ជាទូទៅនិងមានសំណេរជាអក្សរឡាតាំងខុសពីការកំណត់ក្នុងចំណុច II ខាងលើ ត្រូវទុកជាករណីលើកលែង ?

Wikipedia
The Free Encyclopedia

# Romanization of Khmer

The **romanization of Khmer** is a representation of the Khmer (Cambodian) language using letters of the Latin alphabet. This is most commonly done with Khmer proper nouns, such as names of people and geographical names, as in a gazetteer.

## Romanization systems for Khmer

Cambodian geographical names are often romanized with a transliteration system, where representations in the Khmer script are mapped regularly to representations in the Latin alphabet (sometimes with some additional diacritics). The results do not always reflect standard Khmer pronunciation, as no special treatment is given to unpronounced letters and irregular pronunciations, although the two registers of Khmer vowel symbols are often taken into account.

When transcription is used, words are romanized based on their pronunciation. However, pronunciation of Khmer can vary by speaker and region. Roman transcription of Khmer is often done ad hoc on Internet forums and chatrooms, the results sometimes being referred to as *Khmenglish* or *Khmerlish*. These ad hoc romanizations are usually based on English pronunciations of letters, although they may also be influenced by Khmer spelling (as with the use of *s* rather than *h* to represent a final aspirate).

Since some sounds can be represented by more than one symbol in Khmer orthography, it is not generally possible to recover the original Khmer spelling from a pronunciation-based Roman transcription. Even transliteration systems often do not preserve all of the distinctions made in the Khmer script.

Some of the more commonly used romanization systems for Khmer are listed below. For full details of the various systems, see the links given in the External Links section.

### UNGEGN

The Khmer romanization scheme published by the United Nations Group of Experts on Geographical Names is based on the BGN/PCGN system, described below. It is used for Cambodian geographical names in some recent maps and gazetteers, although the

Geographic Department's modified system (see below) has come into use in the country since 1995.[1] Correspondences in the UNGEGN system are detailed in the Khmer alphasyllabary article.

## Geographic Department

The Geographic Department of the Cambodian Ministry of Land Management and Urban Planning has developed a modified version of the UNGEGN system,[2] originally put forward in 1995, and used in the second edition of the Gazetteer of Cambodia in 1996. Further modifications were made in 1997, and the system continues to be used in Cambodia.[1]

The main change made in this system compared with the UNGEGN system is that diacritics on vowels are omitted. Some of the vowels are also represented using different letter combinations.

## BGN/PCGN

A system used by the United States Board on Geographic Names and the Permanent Committee on Geographical Names for British Official Use, published in 1972. It is based on the modified 1959 *Service Géographique Khmer* (SGK) system.[3]

## ALA-LC Romanization Tables

This system (also called Transliteration System for Khmer Script), from the American Library Association and Library of Congress,[4] romanizes Khmer words using the original Indic values of the Khmer letters, which are often different from their modern values. This can obscure the modern Khmer pronunciation, but the system has the advantage of relative simplicity, and facilitates the etymological reconstruction of Sanskrit and Pali loanwords whose pronunciation may be different in modern Khmer. The system is a modification of that

proposed by Lewitz (1969), and was developed by Franklin Huffman of Cornell University and Edwin Bonsack of the Library of Congress for the library cataloguing of publications in Khmer.

# Example words written in each romanization system

| English | Khmer | Romanization | | |
|---|---|---|---|---|
| | | UNGEGN (or BGN/PCGN) | Geographic Department | ALA-LC |
| Khmer script | អក្សរខ្មែរ | *'âksâr khmêr* | *'aksar khmaer* | *ʿ'aksar khmaer* |
| Cambodia | កម្ពុជា | *Kâmpŭchéa* | *Kampuchea* | *Kambujā* |
| centre | មណ្ឌល | *môndôl* | *mondol* | *maṇḍal* |
| brightness | ពន្លឺ | *pônlœ* | *ponlueu* | *banlȳ* |
| peace | សន្តិភាព | *sântĕphéap* | *santepheap* | *santibhāb* |
| belief | ជំនឿ | *chumnœă* | *chumnoea* | *jaṃnẏa* |
| to go | ទៅ | *tŏu* | *tov* | *dau* |

# Tables of romanization systems

This chart shows in full the three main systems for the romanization of Khmer: UNGEGN (or BGN/PCGN), Geographic Department and ALA-LC:

## Consonants

☐ 1st series ☐ 2nd series[note 1]

| Khmer | | | UNGEGN (or BGN/PCGN) | Geographic Department | ALA-LC |
|---|---|---|---|---|---|
| Full form | Subscript form | IPA | | | |
| ក | ្ក | [k] | *ka* | *Ka* | *k* |
| ខ | ្ខ | [$k^h$] | *kha* | *Kha* | *kh* |
| គ | ្គ | [k] | *Ga* | *Go* | *g* |
| ឃ | ្ឃ | [$k^h$] | *Gha* | *Gho* | *gh* |
| ង | ្ង | [ŋ] | *Ṅa* | *Ṅo* | *ng* |
| ច | ្ច | [c] | *Ca* | *Ca* | *c* |
| ឆ | ្ឆ | [$c^h$] | *Cha* | *Cha* | *ch* |
| ជ | ្ជ | [c] | *Ja* | *Jo* | *j* |
| ឈ | ្ឈ | [$c^h$] | *Jha* | *Jho* | *jh* |
| ញ | ្ញ | [ɲ] | *Ña* | *Ño* | *ñ* |
| ដ | ្ដ | [ɗ] | *Ṭa* | *Ṭa* | *ṭ* |
| ឋ | ្ឋ | [$t^h$] | *Ṭha* | *Ṭha* | *ṭh* |
| ឌ | ្ឌ | [ɗ] | *Ḍa* | *Do* | *ḍ* |
| ឍ | ្ឍ | [$t^h$] | *Ḍha* | *Ḍho* | *ḍh* |
| ណ | ្ណ | [n] | *Ṇa* | *Ṇa* | *ṇ* |
| ត | ្ត | [t] | *Ta* | *Ta* | *t* |
| ថ | ្ថ | [$t^h$] | *Tha* | *Tha* | *th* |
| ទ | ្ទ | [t] | *Da* | *Do* | *d* |
| ធ | ្ធ | [$t^h$] | *Dha* | *Dho* | *dh* |
| ន | ្ន | [n] | *Na* | *No* | *n* |
| ប | ្ប | [ɓ], [p] | *Pa* | *Pa,Ba*[note 2] | *p* |
| ផ | ្ផ | [$p^h$] | *Pha* | *Pha* | *ph* |
| ព | ្ព | [p] | *Ba* | *Bo, po* [Note 2] | *b* |
| ភ | ្ភ | [$p^h$] | *Bha* | *Bho* | *bh* |
| ម | ្ម | [m] | *Ma* | *Mo* | *m* |
| យ | ្យ | [j] | *Ya* | *Yo* | *y* |
| រ | ្រ | [r] | *Ra* | *Ro* | *r* |

| | | | | | |
|---|---|---|---|---|---|
| ល | ្ល | [l] | *La* | *Lo* | *l* |
| វ | ្វ | [ʋ] | *Va* | *Vo* | *v* |
| ឝ | ្ឝ | [s] | *Śa* | *sha* | *ś* |
| ឞ | ្ឞ | [s] | *Ṣa* | *Sha* | *ṣ* |
| ស | ្ស | [s] | *Sa* | *Sa* | *s* |
| ហ | ្ហ | [h] | *Ha* | *Ha* | *h* |
| ឡ | — | [l] | *Ḷa* | *La* | *ḷ* |
| អ | ្អ | [ʔ] | *A* | A | *A* |

## Dependent vowels

| Khmer | UNGEGN (or BGN/PCGN) | | Geographic Department | | ALA-LC |
|---|---|---|---|---|---|
| | A-series | O-series | A-series | O-series | A-series |
| ◌◌ | *â* | *ô* | *a* | *o* | *a* |
| ◌់ | *á* | *ó* | *a* | *o* | *á* |
| ◌ា | *a* | *éa* | *a* | *ea* | *ā* |
| ◌ា់, ◌័◌ | *ă* | *eă*, *oă* | *a* | *ea*, *oa* | *â* |
| ◌ះ | *ă* | *eă* | *ak* | *eak* | *à* |
| ◌័យ | *ăy* | *oăy* | *ai* | *ey* | *ăy* |
| ◌ិ | *ĕ* | *ĭ* | *e* | *i* | *i* |
| ◌ី | *ei* | *i* | *ei* | *i* | *ī* |
| ◌ឹ | *œ̆* | *œ̆* | *oe* | *ue* | *ẏ* |
| ◌ឺ | *œ* | *œ* | *eu* | *ueu* | *ȳ* |
| ◌ុ | *ŏ* | *ŭ* | *o* | *u* | *u* |
| ◌ូ | *o* | *u* | *ou* | *u* | *ū* |
| ◌ួ | *uŏ* | *uŏ* | *uo* | *uo* | *ua* |
| ◌ើ | *aeu* | *eu* | *aeu* | *eu* | *oe* |
| ◌ឿ | *œă* | *œă* | *oea* | *oea* | *ẏa* |
| ◌ៀ | *iĕ* | *iĕ* | *ie* | *ie* | *ia* |
| ◌េ | *é* | *é* | *e* | *e* | *e* |
| ◌ែ | *ê* | *ê* | *ae* | *eae* | *ae* |

| | | | | | |
|---|---|---|---|---|---|
| ◌ៃ | *ai* | *ey* | *ai* | *ey* | *ai* |
| ◌ោ | *aô* | *oŭ* | *ao* | *ou* | *o* |
| ◌ៅ | *au* | *ŏu* | *au* | *ov* | *au* |
| ◌ុំ | *om* | *ŭm* | *om* | *um* | *uṃ* |
| ◌ំ | *âm* | *um* | *am* | *um* | *aṃ* |
| ◌ាំ | *ăm* | *ŏâm* | *am* | *oam* | *āṃ* |
| ◌ាំង | *ăng* | *eăng* | *ang* | *eang* | *āṃng* |
| ◌ះ | *ăh* | *eăh* | *ah* | *eah* | *aḥ* |
| ◌ិះ | *ĕh* | *ĭh* | *eh* | *is* | *iḥ* |
| ◌ឹះ | *œ̆h* | *œ̆h* | *oeh* | *ueh* | *ẏḥ* |
| ◌ុះ | *ŏh* | *ŭh* | *oh* | *uh* | *uḥ* |
| ◌េះ | *éh* | *éh* | *eh* | *eh* | *eḥ* |
| ◌ើះ | *aeuh* | *euh* | *aeuh* | *euh* | *oeḥ* |
| ◌ែះ | *êh* | *êh* | *aeh* | *eaeh* | *aeḥ* |
| ◌ោះ | *aôh* | *ŏăh* | *aoh* | *uoh* | *oaḥ* |

## Independent vowels

| Khmer | UNGEGN (or BGN/PCGN) | Geographic Department | ALA-LC |
|---|---|---|---|
| អ | *â* | *a* | *a* |
| អា | *a* | *a* | *ā* |
| ឥ | *ĕ* | *e* | *i* |
| ឦ | *ei* | *ei* | *ī* |
| ឧ | *ŏ, ŭ* | *o, u* | *u* |
| ឩ | *o, u* | *ou, u* | *ū* |
| ឪ | *âu* | *au* | *ẏu* |
| ឫ | *rœ̆* | *rue* | *ṛ* |
| ឬ | *rœ* | *rueu* | *ṝ* |
| ឭ | *lœ̆* | *lue* | *ḷ* |
| ឮ | *lœ* | *lueu* | *ḹ* |
| ឯ | *ê* | *ae* | *ae* |

| | | | |
|---|---|---|---|
| ឰ | *ai* | *ai* | *ai* |
| ឱ, ឲ | *aô* | *ao* | *o* |
| ឳ | *au* | *au* | *au* |

# International Phonetic Alphabet transcription

Various authors have used systems based on the International Phonetic Alphabet (IPA) to transcribe Khmer. One such system is used in the books of Franklin E. Huffman and others;[5] a more recent scheme is that used in J.M. Filippi's 2004 textbook *Everyday Khmer* or *Khmer au quotidien*.[6] These systems differ in certain respects: for example, Huffman's uses doubling of vowel symbols to indicate long vowels, whereas Filippi's uses the IPA triangular colon vowel length symbol.

# Notes

1. Khmer consonants belong to two classes that dictate the value of dependent vowels.
2. When accompanied by a subscript form, it is romanized as *p* in the 1st series, although the Khmer diacritical mark ៉ is generally omitted: ប្លែង → *plaeng*, ប្អូន → *p'oun*, ប្រាប់ → *prab*.

# References

1. Report on the Current Status of United Nations Romanization Systems for Geographical Names – Khmer (http://www.eki.ee/wgrs/rom1_km.pdf), UNGEGN Working Group on Romanization Systems, September 2013 (linked from WGRS website (http://www.eki.ee/wgrs/)).
2. Geographical Names of the Kingdom of Cambodia (https://unstats.un.org/unsd/geoinfo/UNGEGN/docs/8th-uncsgn-docs/inf/8th_UNCSGN_econf.94_INF.30.pdf), submitted by Cambodia to the 8th UN Conference on the Standardization of Geographical Names, 2002 (also addendum with corrections (http://unstats.un.org/unsd/geoinfo/UNGEGN/docs/8th-uncsgn-docs/inf/8th_UNCSGN_econf.94_INF.30_corr1.pdf)).
3. Romanization System for Khmer (Cambodian) (https://www.gov.uk/government/uploads/system/uploads/attachment_data/file/320109/Khmer_Romanization_Nov12.pdf), BGN/PCGN 1972 System.
4. ALA-LC Romanization Tables (https://www.loc.gov/catdir/cpso/roman.html), Khmer, rev. 2012.
5. For example, Franklin E. Huffman, *Cambodian System of Writing and Beginning Reader with Drills and Glossary*, Adam Wood, 1970 (downloadable PDF (http://www.pratyeka.org/csw)).

6. Jean Michel Filippi, *Everyday Khmer*, Funan, Phnom Penh , 2004. French edition: Filippi et al., *Khmer au quotidien*, Librairie You-Feng, 2008.

# External links to romanization tables

- UNGEGN (http://www.eki.ee/wgrs/rom1_km.pdf) (PDF - 166kb)
- Geographic Department (http://unstats.un.org/unsd/geoinfo/UNGEGN/docs/8th-uncsgn-docs/inf/8th_UNCSGN_econf.94_INF.30_corr1.pdf) (PDF)
- ALA-LC (https://www.loc.gov/catdir/cpso/romanization/khmer.pdf) (PDF - 1,064kb)
- BGN/PCGN (https://www.gov.uk/government/uploads/system/uploads/attachment_data/file/320109/Khmer_Romanization_Nov12.pdf) (PDF - 334.49kb)

Retrieved from "https://en.wikipedia.org/w/index.php?title=Romanization_of_Khmer&oldid=1188265523"

